01389895

E1/508.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2017, 13:32
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៤៨៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

ហាសាន អាធុរេលិយ៉ា
*(Mr. HARSHAN Athureliya)*

លោក ឯម ហ៊ីយ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វលក្ស

លោក ខលវីន សោនឌឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និន ណុល (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេសន៍ | អង់គ្លេស |
| ចៅក្រម យូរ ឧត្តរា | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក នួន ត្រិច (2-TCW-1060) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នួន ត្រិច/ទេស ត្រិច** (2-TCW-1060)

សួរបន្តដោយលោក ឌេល លីសាក់ ផ្ដើមពី ........................................................ ទំព័រ ២

សួរដោយលោក ហុង គឹមសួន ផ្ដើមពី ........................................................ ទំព័រ ៨

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី ........................................................ ទំព័រ ១៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:១២]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី នួន ត្រិច បញ្ចប់។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ាយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ក្រឡាបញ្ជីរួចហើយ។

នៅថ្ងៃនេះ សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក នួន ត្រិច។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៤:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊ាយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយ

ផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ និងឈឺកាន់ខ្លាំងបើសិនជាអង្គុយយូរ ហើយនិងវិលមុខ និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:០៨]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវី -- សហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញារង រួមទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលតែ៤៥នាទីទៀតប៉ុណ្ណោះ ក្នុងការសួរដេញដោលសាក្សីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំមានសំណួរសម្រាប់តែរយៈប្រហែលជា១០ ទៅ១៥នាទីទៀតទេ ហើយនឹងប្រគល់ពេលវេលានេះជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវខ្ញុំបន្តសួរអំពីការដ្ឋានព្រលាន

យន្តហោះកំពង់ឆ្នាំង។ ហើយយើងក៏បាននិយាយគ្នាអំពីការរងរបួស ឬក៏ការស្លាប់ដោយសារតែការផ្ទុះផ្លូននៅឯព្រលានយន្តហោះកំពង់ឆ្នាំងនោះ។ អ៊ីចឹងយោងតាមចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា នេះគឺ E3/7537, ខ្មែរ 00019648, បារាំង 00291006, អង់គ្លេស 00251256។ លោកឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ប្រជាជនជាច្រើនបានស្លាប់ដោយសារតែការបំផ្ទុះផ្លូនក្នុងមួយថ្ងៃៗ។" ក៏ប៉ុន្តែយោងតាមប្រតិចារឹកដែលលើកឡើងដោយមេធាវីការពារក្តីតាមរយៈកំណត់ត្រាខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍របស់លោក <ជាមួយនឹងការិយាលសហចៅក្រមស៊ើបអង្កេត> គឺក្នុងឯកសារ E3/7877.1 អ្វីដែលលោកបាននិយាយ គឺអ្វីដែលលោកបានឃើញពលករហ្នឹង គឺបានរងរបួសយ៉ាងធ្ងន់ធ្ងរពីការផ្ទុះគ្រាប់ ហើយដែល<ត្រូវបានគេនាំយកទៅកាន់>មន្ទីរពេទ្យ ហើយលោកមិនដឹងថាអ្នកដែលរងរបួសទាំងនោះរស់ ឬក៏ស្លាប់នោះទេ។ តើត្រឹមត្រូវដែរឬទេ លោកសាក្សីថា អ្វីដែលលោកបានឃើញផ្ទាល់ភ្នែក ថាមានពលករទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ ដោយសារការផ្ទុះគ្រាប់បែកហ្នឹង? អ៊ីចឹងសូមលោកបញ្ជាក់មើល ថាតើ<លោកធ្លាប់បានឮថា>មានពលករណាម្នាក់ស្លាប់ពីការរងរបួសដោយសារការ<ផ្ទុះហ្នឹង>ដែរឬទេ?

[០៩:០៩:០៥]

**លោក នួន ត្រិច៖**

**ឆ៖** ខ្ញុំបានឃើញនៅពេលនុ៎ង ពេលរបួសហ្នឹង ដល់គេយកទៅពេទ្យ ខ្ញុំក៏អត់ដឹងថាស្លាប់ ឬរបួសដែរ ព្រោះគេដឹកយកទៅពេទ្យកំពង់ឆ្នាំង ព្រោះព្រលានយន្តហោះហ្នឹង វានៅឆ្ងាយពីខេត្តកំពង់ឆ្នាំង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំតាមរយៈ*កាណាល់*អង់គ្លេស គឺថាខ្ញុំស្ដាប់អង់គ្លេសអត់បានទេ អត់ឮទេ។ អ៊ីចឹងលោក លោកស្រីចៅក្រមយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

ទំនងភាគីដទៃទៀតស្ដាប់យល់ហើយ ហើយបែបគាត់មានបញ្ហាឧបករណ៍ស្ដាប់សំឡេងរបស់គាត់ដឹង?

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំស្ដាប់ចម្លើយលោកអម្បាញ់មិញអត់ឮទេ។ អ្វីដែលខ្ញុំចង់សួរបន្តពីចំណុចអម្បាញ់មិញនេះ មុនពេលលោកទៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង លោកធ្លាប់បានធ្វើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការពីរបីឆ្នាំជាពេទ្យ ព្យាបាលកងទ័ពដែលរងរបួស តើមានមេៗលោកណាម្នាក់នៅឯការដ្ឋានកំពង់ឆ្នាំងហ្នឹង ស្នើសុំឱ្យលោកហ្នឹងជួយព្យាបាលពលករដែលរងរបួសនោះដែរឬទេ?

[០៩:១០:៥៧]

**លោក នួន ត្រិច៖**

**ឆ៖** ពេលនុ៎ងខ្ញុំអត់មានសិទ្ធិ គឺធ្វើជាពេទ្យទេ ព្រោះពេលនុ៎ង ខ្ញុំសិទ្ធិជាអ្នកទោសខាងជីកថ្ម ខាងជីកដី មិនមានសិទ្ធិគេឱ្យធ្វើពេទ្យទៀតទេ គេដកសិទ្ធិពីពេទ្យហើយ ព្រោះខ្ញុំជា គេជនចោទ ថាជនក្បត់ ក.ហ្សេ.បេ, សេ.អ៊ី.អា ព្រោះខ្ញុំនៅជំនាន់នុ៎ង ខ្ញុំអត់ដឹងថា ក.ហ្សេ.បេ, សេ.អ៊ី.អា របៀបម៉េចទេ ព្រោះគេថា ខ្ញុំហ្នឹងជាជនក្បត់។

**ស៖** សូមអរគុណ។ តើ<នរណាជា>ពលករដែលធ្វើការនៅកន្លែងជាមួយនឹងលោក <នៅកន្លែងដែលគេប្រើគ្រឿង>ផ្ទុះ<> ដើម្បីបំបែកថ្ម<ធ្វើរូងក្រោមដីហ្នឹង តើពួកគាត់ជាអ្នកណា>?

**ឆ៖** នៅពេលនោះ ចម្រុះវរៈ កងពល ព្រោះដែលថា កងពល៣១០នុ៎ង មានកងពលធំ កងពលតូច វរសេនាតូច វរសេនាធំ គឺច្រើន ព្រោះទៅចម្រុះ ទៅកន្លែងនុ៎ង។ ខ្ញុំអត់សូវបានស្គាល់ទេ ខ្ញុំស្គាល់តែក្នុងវរសេនាតូចខ្ញុំ ព្រោះខ្ញុំទៅហ្នឹង ទៅកន្លែងនុ៎ង មានតែខ្ញុំមួយទេ ព្រោះទីកន្លែងចម្រុះ កន្លែងធ្វើការអ្នកដែលជាប់ទោស។

**ស៖** តើលោកដឹងទេ ថានៅទីតាំងហ្នឹង មានពលករណាមកពីភមិភាគបូព៌ាដែរឬទេ?

**ឆ៖** មានដែរ តែខ្ញុំអត់ស្គាល់ ព្រោះធ្វើការហ្នឹង ខ្លះថាមកពីភូមិភាគបូព៌ា ខ្លះថាមកពីភូមិភាគខាងទ័ព ខាងឧត្តរ។

**ស៖** នៅឯការដ្ឋានដែលគេដាក់បំផ្ទុះថ្មហ្នឹង ដើម្បីបំបែកយកថ្មហ្នឹង តើមានជំនាញការចិននៅទីនោះដែរទេ?

[០៩:១៣:២៧]

**ឆ៖** ជំនាញការដូចជាចិនហ្នឹង គេអ្នកខាងវិស្វករ គេគ្រាន់តែមកប្រាប់យើងឱ្យធ្វើមួយកន្លែតៗទេ ដូចថាព្រលានហ្នឹងដំថ្ម ជីកដីហ្នឹងជម្រៅប៉ុន្មាន ដូចជាមានខ្មៅ ដូចជាមានសំរាម ជម្រៅ៥ម៉ែត្រ ចិនហ្នឹងគេថា ឱ្យយើងហ្នឹងជីកយកចេញ ខ្លាចកប៉ាល់ហោះហ្នឹងចុះទៅស្រុត។

**ស៖** កាលពីម្សិលមិញលោកថា ដុំថ្មដែលបែកដោយសារតែការបំផ្ទុះ<ផ្នែកម្ខាងទៀតនៃភ្នំ>ហ្នឹង គេយកទៅប្រើប្រាស់ដើម្បីយកទៅចាក់ធ្វើជាផ្លូវយន្តហោះ។ តើគេដឹកជញ្ជូនថ្មទាំងអស់ហ្នឹងទៅ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រលានយន្តហោះនុ៎ង ដើម្បីយកថ្មទៅធ្វើផ្លូវយន្តហោះហ្នឹង គេដឹកជញ្ជូនដោយរបៀបណា?

**ឆ៖** ដឹកពេលនុ៎ងគេប្រើដោយកម្លាំងពលករមនុស្ស ហើយឡានដែលគេមកដឹកហ្នឹង ឡានមួយៗទេ ភាគីច្រើនប្រើពលករ កម្លាំងមនុស្ស។

**ស៖** ចុះអ្នកដែលត្រូវដឹកជញ្ជូនថ្មចេញកន្លែងបំផ្ទុះហ្នឹង ទៅព្រលានហ្នឹង តើវាមានចម្ងាយប៉ុន្មានដែរ?

**ឆ៖** ចម្ងាយនុ៎ង មិនឆ្ងាយពីព្រលានប៉ុន្មានទេ ចម្ងាយប្រហែលដូចជាថា មិនដល់១គីឡូទេ ព្រោះជំនាន់នុ៎ង ពលករខ្មែរហ្នឹង ពលករដែលជាប់ហ្នឹង ត្រូវសែងធ្វើជាដំដែកអៀមប៉ាន់នុ៎ង ដាក់សែង។

**ស៖** ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារក្នុងការដឹកជញ្ជូនថ្មទាំងអស់អ៊ីចឹង តើពលករទាំងនោះទទួលរបបអាហារហ្នឹង បានប៉ុន្មានពេលដែរ ក្នុងមួយថ្ងៃ?

**ឆ៖** ពលករនៅពេលនុ៎ង ទទួលអាហារហូបចុកហ្នឹង បានមួយថ្ងៃតែពីរពេលទេ ព្រោះហូបមានរបប។ របបហ្នឹង មានតែមួយចានទេ គឺបាយលាយ អត់មានបាយសុទ្ធទេ។

**ស៖** របបអាហារដែលលោកទទួលបានហ្នឹង ជាបាយរឹងហ្នឹង ឬក៏ជាបបរទេ?

**ឆ៖** ជាបាយ តែបាយហ្នឹង គេលាយចេក ព្រោះបាយហ្នឹង ចេក បាយហ្នឹងភាគតិច ចេកភាគច្រើន។

[០៩:១៦:៥០]

**ស៖** តើស្ថានភាពសុខភាពរបស់ពលករ ដែលធ្វើការនៅទីនោះយ៉ាងដូចម្តេចដែរ? តើលោក<មានសុខភាពល្អទេ? តើលោក>អាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ពលករទាំងអស់ហ្នឹង <និងរូបលោកផ្ទាល់ហ្នឹង> មានសុខភាពរបៀបណាដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន-->

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរបែបនេះ។ ជាការពិតហើយ គឺថាសាក្សីគាត់អាចផ្តល់

សក្ខីកម្ម ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារនៃពលករដែលធ្វើការជាមួយគាត់។ ប៉ុន្តែខ្ញុំថា នៅពេលមួយនោះ គឺថាមានពលកររហូតដល់ ២០.០០០នាក់ឯណោះ ធ្វើការ<ដើម្បីបញ្ចប់>ព្រលានយន្តហោះកំពង់ឆ្នាំងនុ៎ង។ ដូច្នេះ សហព្រះរាជអាជ្ញារង គឺថាសុំសួរធ្វើម៉េចឲ្យភ្ជាប់តែទៅនឹងសាក្សី ហើយនិងស្ថានភាពជុំវិញខ្លួនគាត់ទេ ពីព្រោះមានមនុស្សច្រើនណាស់។

[០៩:១៧:៥០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** គឺថាខ្ញុំសូមសួរអំពីលក្ខខណ្ឌការងារសម្រាប់លោកផ្ទាល់ និងអ្នកដែលនៅជុំវិញលោកដែលលោកអាចកត់សម្គាល់បាន។ តើលោកអាចជម្រាប<បានទេ អំពី>ស្ថានភាពសុខភាព<របស់លោក និងអ្នកដែលធ្វើការជាមួយលោកនោះ> យ៉ាងម៉េចដែរ?

**លោក នួន គ្រិច៖**

**ឆ៖** សុខភាពពលករនៅកន្លែងនុ៎ង មិនសូវអ្នក មានអ្នកធាត់ទេ ព្រោះកន្លែងនុ៎ង កន្លែងលត់ដំសុទ្ធតែស្គមៗទេ។

**ស៖** តើគេតម្រូវឲ្យលោកធ្វើការក្នុងមួយថ្ងៃប៉ុន្មានម៉ោងដែរ? នៅពេលដែលគេផ្តល់របបអាហារហ្នឹង តែពីរពេលទេក្នុងមួយថ្ងៃ អ៊ីចឹងចំពោះការងារវិញ លោកធ្វើប៉ុន្មានម៉ោងដែរ ក្នុងមួយថ្ងៃ?

**ឆ៖** ពីម៉ោងបួនជិតភ្លឺ ដល់ម៉ោងមួយដណ្តប់។ ពេលល្ងាចពីម៉ោង ឈប់បានមួយម៉ោង ចាប់ពីម៉ោងពីរដណ្តប់ ទល់ម៉ោងប្រាំល្ងាច។

**ស៖** ចុះតើគេតម្រូវឲ្យលោកធ្វើការនៅពេលយប់ដែរទេ? ហើយបើមានធ្វើការនៅពេលយប់ តើការងារពេលយប់នោះ ធ្វើញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ពេលយប់នុ៎ង ធ្វើការជារៀងរាល់ថ្ងៃ ពីម៉ោងប្រាំមួយល្ងាចទៅហ្នឹង ទល់ម៉ោងដប់យប់។

**ស៖** នៅឯការដ្ឋានការងារនៅពេលដែលគេតម្រូវឲ្យលោកធ្វើការនៅពេលយប់ គេមានបំភ្លឺភ្លើងអីដែរទេ?

[០៩:១៩:៤៩]

**ឆ៖** ពេលនុ៎ង គេដាក់ភ្លើងភ្លឺគ្រប់កន្លែង អត់ឲ្យមានយើងងងឹតទេ។

**ស៖** ខ្ញុំសូមសួរចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7537, ខ្មែរ 00019649, អង់គ្លេស 00251256, បារាំង 00291007។ លោកបានឆ្លើយដូចតទៅ៖ “សួរ៖ តើ

ការងារនៅទីនោះលំបាកទេ? ឆ្លើយ៖ ការជីកថ្មនេះ គឺថាពិបាកមែនទែន ពីព្រោះយើងត្រូវជីកជម្រៅ ៥ម៉ែត្រ<យកសំរាមចេញ> យើងធ្វើការទាំងយប់ទាំងថ្ងៃ។ សួរ៖ តើហេតុអ្វីគេឱ្យលោកជីកថ្ម? ឆ្លើយ៖ គេខ្លាចស្រុតជើង យន្តហោះនោះនៅពេលយន្តហោះចុះ <បើមានសំរាមនៅក្នុងដី>។ អ៊ីចឹងយើងខ្លាចគេដាក់ទណ្ឌកម្មណាស់ អ៊ីចឹង ពួកយើងខ្ញុំនេះ គឺថាត្រូវធ្វើការយ៉ាងលំបាក។" បញ្ចប់ការដកស្រង់។ អ្វីដែលខ្ញុំចង់សួរលោកនៅពេលនេះ លោកសាក្សី តើហេតុអ្វីបានជាលោកឆ្លើយថា លោកត្រូវតែធ្វើការ<ខ្លាំង> ពីព្រោះថាលោកខ្លាចគេដាក់ទណ្ឌកម្ម? ហេតុអីបានជាលោកខ្លាចគេដាក់ទណ្ឌកម្ម?

**ឆ៖** ពេលហ្នឹងគេចាត់តាំង គេថា ពួកខ្ញុំហ្នឹងសុទ្ធតែពួកក្បត់ អ៊ីចឹងគេឱ្យមកកសាងខ្លួន។ បើកសាងតាមមិនទាន់ប្រវត្តិសាស្ត្រទេ វាមិនអាច -- នឹងអាចស្លាប់ខ្លួន ព្រោះដូចខ្ញុំមានប្រសាសន៍ថ្ងៃមុន អ៊ីចឹង ថាកងចក្រ គេកំពុងដំណើរវិល អ៊ីចឹងបើយើងថា ដើរមិនទាន់ទេ វាប៉ះកងចក្រវិល បើលោកវិលមិនទាន់ ត្រូវដាច់ជើងដាច់ដៃ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកឆ្លើយដូចគ្នា ថាលោកត្រូវ<បានគេប្រមាន គឺត្រូវតែធ្វើការដូចចលនាកង់វិល។ ហើយលោកបាននិយាយថា> មេរបស់លោកបាន<និយាយរឿងហ្នឹងនៅក្នុងកិច្ច>ប្រជុំ។ តើគេប្រជុំនៅកន្លែងណា ដែលថា<គេព្រមានលោកថា> ត្រូវតែខិតខំប្រឹងប្រែងបន្តធ្វើការងារដូចចលនាកង់វិល? តើលោកចាំថា> តើប្រធាន<ដែលនិយាយរឿងហ្នឹងជានរណាដែរ>?

[០៩:២២:៤៦]

**ឆ៖** ពេលនៅកំពង់ឆ្នាំងហ្នឹង ពួកខ្ញុំហ្នឹង ជាអ្នកនេះហ្នឹង គេឱ្យនៅនឹងខេត្តកំពង់ឆ្នាំង -- អ៎! នៅនឹងជិតព្រលានហ្នឹង ព្រោះមានមេគេហ្នឹង ខាងភូមិភាគនិរតី ដែលគេមកប្រជុំហ្នឹង គេអ្នកសម្រាប់ថា យើងអ្នកដែលមានទោសកំហុសហ្នឹង មកប្រជុំ។ គេឱ្យយើងហ្នឹងធ្វើការប្រឹងប្រែង ដើម្បីឱ្យលុតដំឱ្យរួចពីទោស ក្រែងធ្វើការមិនទាន់ប្រវត្តិសាស្ត្រ អាចនឹងមានទោសតទៅទៀត។

**លោក ឌេល លីសាក់៖**

សូមអរគុណច្រើនលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាតទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមលោកប្រធាន អនុញ្ញាតឲ្យលោកមេធាវី ហុង គឹមសួន សួរសំណួរទៅលើសាក្សីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

សូមអញ្ជើញលោកមេធាវី ហុង គឹមសួន!

[០៩:២៤:០៥]

**លោក ហុង គឹមសួន៖**

បាទ ខ្ញុំបាទសូមគោរពលោកប្រធាន និងសូមគោរពលោកស្រី លោកចៅក្រមជំនុំជម្រះជាទីគោរព។ សូមគោរពអង្គសវនាការ និងសូមថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ ដែលចូលរួមក្នុងសវនាការថ្ងៃនេះ។ ខ្ញុំបាទ មេធាវី ហុង គឹមសួន ជាមេធាវីនៃអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរបន្តិចបន្តួច តែលម្អិតខ្លះៗ តពីលោកសហព្រះរាជអាជ្ញាបន្តទៅទៀត។ ទាក់ទងជាមួយនឹងការងាររបស់លោកជាពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា។ សំណួរខ្ញុំចាប់ផ្ដើមអំពីសួរថាតើពេលដែលចូលមកដល់ទីក្រុងភ្នំពេញ ក្រោយពេលបែកទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ មេសា ១៩៧៥ហ្នឹង តើកងរបស់លោកជាកងទ័ព ឬក៏ជាកងស៊ីវិលមករួមគ្នា?

**លោក នួន ត្រិច៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! កុំអាលទាន់! ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការទេ!

[០៩:២៥:១៥]

**លោក នួន ត្រិច៖**

**ឆ៖** ខ្ញុំនៅពេលនុ៎ងខ្ញុំជាពេទ្យភូមិភាគ ហើយគេថាត្រូវវ៉ៃទាហាន លន់ នល់ គេដាក់ទិសថាឲ្យ

ឆ្នាំ៧៥ហ្នឹង គឺឲ្យវ៉ៃដាច់គ្រប់កន្លែងគ្រប់ មុខព្រួញ។ អ៊ីចឹង--

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សូមកាត់ប្រសាសន៍លោក សំណួរខ្ញុំសួរអ៊ីចេះ សួរថាវ៉ៃដាច់ទីក្រុងភ្នំពេញហើយ ពេលដែលចូលមកដល់ទីក្រុងភ្នំពេញហ្នឹង កងរបស់លោកហ្នឹងទោះបីកងពេទ្យនៅក្នុងកងទ័ពក៏ដោយ សុទ្ធសឹងជាកងទ័ព ឬមានជាក្រុមជនស៊ីវិលមកនៅម្តុំពេទ្យ ឬក៏នៅក្នុងកងរបស់លោកហ្នឹងដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណា ឲ្យសញ្ញាភ្លើងក្រហមសិន។

**លោក នួន ត្រិច៖**

**ឆ៖** នៅពេលនុ៎ងសុទ្ធតែពេទ្យក៏ពេទ្យក្នុងកងទ័ពដែរ សុទ្ធតែកងទ័ពទេចូលទីក្រុងភ្នំពេញហ្នឹង អត់មានស៊ីវិលទេ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** បាទ សូមអរគុណ។ ពីម្សិលមិញលោកបានឆ្លើយនឹងសំណួរលោកព្រះរាជអាជ្ញា ទាក់ទងជាមួយនឹងការចាប់មេរបស់កងរបស់លោក ឈ្មោះ អឿន ព្រមទាំងយកប្រពន្ធកូនគាត់ទៅដែរ។ អ៊ីចឹងសំណួរខ្ញុំសួរថាតើប្រពន្ធកូនរបស់មេតែមួយគ្រួសារហ្នឹង ឬក៏មានប្រពន្ធកូន ឬក៏មានជនស៊ីវិលផ្សេងៗទៀតមកនៅក្នុងកងហ្នឹងដែរទេ?

**ឆ៖** ជំនាន់ហ្នឹងអត់មាន--

[០៩:២៦:៤៧]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ ការជាប់ពាក់ព័ន្ធ <នៅក្នុង>សំណួរនេះ គឺថាប្រពន្ធរបស់មេបញ្ជាការ<កងពល> អឿន នេះគឺថាត្រូវបានចាប់ខ្លួនដោយសារ <គាត់ជាប្រពន្ធរបស់ អឿន>។ គេចាប់ខ្លួនប្រពន្ធគាត់នេះដោយសារតែមានការចោទប្រកាន់ថា គឺប្រពន្ធរបស់គាត់ហ្នឹងចូលរួមពាក់ព័ន្ធក្នុង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការបះបោរ ធ្វើរដ្ឋប្រហារនេះដូចគ្នា។ ហើយមានការបញ្ជាក់ច្បាស់ហើយ ថាគាត់គឺជាប្រពន្ធរបស់ អឿន ហើយគាត់ក៏ជាប្រធានមន្ទីរពេទ្យផងដែរ។ អ៊ីចឹងការយកសំណួរនេះដើម្បីយកមកសួរឲ្យមានការពាក់ព័ន្ធនេះ គឺថាមិនជាការត្រឹមត្រូវទេ។ <ដូច្នេះ គួរតែរៀបចំសំណួរនេះឡើងវិញ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នៅពេលនេះយើងទើបតែចាប់ផ្តើមសួរ តើ<រៀបសំណួរឡើងវិញយ៉ាងម៉េច> បើមិនសួរបែបនេះ? ជាសំណួរដែលសួរបន្តទេតើ ថាគេចាប់ខ្លួនឬក៏អត់យ៉ាងណាអ៊ីចឹង។ អ៊ីចឹងហេតុអីក៏បានជាជំទាស់ការទើបតែតាំងសំណួរដើមដំបូងបែបនេះអ៊ីចឹង?

[០៩:២៨:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែការឆ្លើយពាក់ព័ន្ធនេះ គឺវាច្បាស់ហើយថា<វាជាការសន្មតជាមូលដ្ឋានថា> នៅពេលដែលគេចាប់មេបញ្ជាការ<ម្នាក់>ទៅ ប្រពន្ធរបស់គាត់ក៏<អាច>ត្រូវគេចាប់ខ្លួននោះដែរ។ អ៊ីចឹង<វាគឺជាសន្មត ហើយ>ការសួរបែបនេះមិនត្រឹមត្រូវទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ការដែលសួរបែបនេះ គឺមានន័យថា វាអាចឲ្យសួរសំណួរបន្តបន្ទាប់មកទៀត ហើយនិងវាការពាក់ព័ន្ធហើយ ព្រោះនេះទើបតែសំណួរដំបូង។

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ ប្រសិនបើវានឹងទៅអ៊ីចឹងមែននោះ ខ្ញុំទទួលយកបាន។>

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** អ៊ីចឹងខ្ញុំបាទ សូមអនុញ្ញាតបន្តសំណួររបស់ខ្ញុំបាទទៀត។ ក្រោយពេលដែលគេចាប់ប្រពន្ធរបស់ឈ្មោះ អឿន ហ្នឹងទៀត តើមានការចាប់ប្រពន្ធកូនរបស់បុគ្គលិកនៅក្នុងកងឯកភាពក្រោមបង្គាប់បញ្ជាលោក អឿន ហ្នឹងដែរឬទេ?

[០៩:២៩:០៧]

**លោក នួន គ្រិច៖**

**ឆ៖** ពេលនុ៎ងគេថា ភូមិភាគឧត្តរក្សត់ និងភូមិភាគ និងកងទ័ពកងពល៣១០ និងខាងភូមិភាគ ២០៣ ខាងបូព៌ាក្សត់ ពេលនុ៎ងគេចាប់បន្តៗ តែខ្ញុំពេលនុ៎ងខ្ញុំឃើញអ្នកមានប្តីប្រពន្ធមក តែឃើញគេចាប់

បន្តៗ តែមិនដឹងគេយកទៅខាងណាទេ បាត់ខ្លួនអត់ឃើញគ្រប់គ្នា។

**ស៖** បាទ អ៊ីចឹងលោក សំណួរខ្ញុំសួរចង់ជាក់លាក់ ថាតើមានចាប់ប្រពន្ធកូនអ្នកផ្សេងៗទៀត ព្រោះលោកឆ្លើយមកថាមានចាប់បន្តបន្ទាប់ហ្នឹង។ ចង់ឲ្យលោកបញ្ជាក់អ៊ីចេះថាប្រពន្ធកូនរបស់អ្នកផ្សេងទៀតហ្នឹង ប្រពន្ធកូនមិនមែនតែចំពោះ អឿន ទេ ចាប់បន្តបន្ទាប់ហ្នឹងមានទេ មានស្រីប្រុសផ្សេងដែលជាសាច់ញាតិរបស់បុគ្គលិកផ្សេងទៀតដែរទេ ដែលត្រូវបានចាប់ក្រោយឈ្មោះ អឿន ឬក៏ប្រពន្ធ អឿន នេះ?

**ឆ៖** ពេលនុ៎ងមានចាប់បន្តៗ ដូចជានៅក្នុងវរៈខ្ញុំ៣១៣ហ្នឹង មានឈ្មោះ តាវ៉ែន ដែលជាតៃកុងឡាន ក៏គេចាប់ទាំងប្តីទាំងប្រពន្ធទៅបាត់ដែរ ព្រោះមិនដឹងគេយកទៅខាងណាទេ ពេលនុ៎ងគេដឹកយកទៅដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរទាក់ទងជាមួយនឹងចម្លើយ សំណួរចម្លើយម្សិលដែរ លោកថានៅក្នុងកងពលដែលលោកធ្វើការហ្នឹង មានកងធ្វើស្រែ ធ្វើចម្ការដែលស្ថិតនៅក្នុងកងឯកភាពតែមួយ។ អ៊ីចឹងពាក្យថា "អ្នកទៅធ្វើស្រែ ធ្វើចម្ការ" ហ្នឹងសុទ្ធសឹងជាកងទ័ព ឬក៏មានជាប្រពន្ធកូន ឬក៏យុវជនយុវនារីអ៊ីចឹងដែរ មានដែរទេ?

**ឆ៖** នៅពេលនុ៎ងកងទ័ពអត់មានប្រពន្ធទេ មួយៗសុទ្ធតែនៅលីវទាំងអស់គ្នា ព្រោះអ្នកធ្វើស្រែចម្ការហ្នឹងសុទ្ធតែទ័ពនៅលីវ។ ហើយនៅវរៈ៣១៤ហ្នឹង អ្នកមានប្រពន្ធកូនហ្នឹងមានតិចណាស់ ព្រោះក្រៅពីហ្នឹងសុទ្ធតែអ្នកនៅលីវទាំងអស់។

[០៩:៣១:១៦]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកទាក់ទងជាមួយនឹងចម្លើយរបស់លោកដែលបានសម្ភាសនៅជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាដែលលោកនិយាយថា៖ "ឆ្នាំ៧៦ គេចាប់ប្រធានខ្ញុំ គេចាប់តាមខ្សែ គេចោទថាក្បត់ រួចគេចាប់ខ្ញុំដែរ"។ ខ្ញុំសូមលើកឯកសារលេខ E3/7537 ត្រង់ចំណុចលេខ ERN ជាភាសាខ្មែរ 00019645, ERN ជាភាសាអង់គ្លេស 00251253។ លោកអាចជម្រាបបានទេពាក្យថា "ចាប់តាមខ្សែ"ហ្នឹង តើមានន័យយ៉ាងម៉េច? ខ្សែអ្នកតូចមក អ្នកធំមកអ្នកតូចបន្តបន្ទាប់ ឬខ្សែភូមិភាគ ឬក៏ខ្សែតំបន់អី សូមពន្យល់អានេះតិច?

**ឆ៖** ពេលនុ៎ងចាប់តាមខ្សែហ្នឹង គេថាភូមិហើយនិងកងទ័ពហ្នឹង គេថាសុទ្ធជាអ្នកក្បត់ អ៊ីចឹងគេនឹងចម្រាញ់ចាប់បណ្តើរៗ ឲ្យទាល់តែអស់ ព្រោះពេលនុ៎ងគេថា ពួកកងពល៣១០ហ្នឹងជាកងពលដែល

មេក្បត់ហើយ កូនចៅក៏ក្បត់ដែរ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញលោកបានជម្រាបជូនលោកសហព្រះរាជអាជ្ញាស្តីអំពីការចោទប្រកាន់ក្បត់ថា ខ្មែរយៈយួន ឬថា សេ.អ៊ី.អា, កា.ហ្សេ.បេ។ តើគេៗមុននឹងចាប់ ឬក៏មុននឹងចោទហ្នឹង គេមានពន្យល់ទេពាក្យថា "ក្បត់ចូលសេ.អ៊ី.អា ឬចូល កា.ហ្សេ.បេ" ហ្នឹងមានពន្យល់ពាក្យអំពីការក្បត់បែបហ្នឹងទេ?

**ឆ៖** ពេលនុំងគេអត់មានពន្យល់ទេ ព្រោះខ្ញុំនៅក្មេងដែរវីកហ្នឹងនៅ២០អី ព្រោះខ្ញុំគេថា កា.ហ្សេ.បេ ហ្នឹង ខ្ញុំមិនដឹងថា កា.ហ្សេ.បេ របៀបម៉េច សេ.អ៊ី.អា របៀបម៉េច។ ដល់គេថាអ៊ីចឹង ខ្ញុំអត់មានដឹងថា អាកា.ហ្សេ.បេ ហ្នឹងជាខ្មែរអី សេ.អ៊ី.អា មិនដឹងខ្មែរអី ព្រោះគេមកហ្នឹងគេលើកអ៊ីចឹង។

[០៩:៣៣:៥០]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមថយទៅក្រោយបន្តិច ទាក់ទងនឹងចម្លើយរបស់លោកផងដែរ នៅក្នុងចម្លើយដែលលោកនិយាយអំពីទាក់ទងនៅមន្ទីរពេទ្យព្រះកេតុមាលា ថាមានចិន, មានកូរ៉េ ឬជំនួយការចិន កូរ៉េ មកធ្វើការ ឬក៏ជំនួយការនៅមន្ទីរពេទ្យហ្នឹង។ សំណួរខ្ញុំ ៗលើកឡើងនៅក្នុងឯកសារលេខ E3/7537, ERN ជាភាសាខ្មែរ 00019644, ERN ជាភាសាអង់គ្លេស 00251252។ កន្លែងនេះខ្ញុំចង់សួរថា តើជំនួយការចិន ឬកូរ៉េដែលមកធ្វើការជំនួយការពេលនុំង មានថ្នាក់ដឹកនាំខ្មែរក្រហមណាដែលគេជូនមក ឬក៏អមដំណើរមកជាមួយដែរទេ? ហើយលោកស្គាល់គេទេ?

**ឆ៖** ពេលនុំងជំនួយការចិនគេចុះមកដើរមកកន្លែងមន្ទីរពេទ្យនុំង ដូចជាខ្ញុំអត់ស្គាល់គេអ្នកធំទេ ព្រោះឃើញចិនគេមកហ្នឹង ខ្ញុំស្គាល់តែចិន គេនិយាយចិន តែបើអ្នកធំ ខ្ញុំអត់ស្គាល់គេទេ ព្រោះមិនដឹងគេធ្វើអីៗ ឃើញគេមកជាមួយ។

**ស៖** បាទ នៅឯកសារដដែល លោកបាននិយាយអំពីថាឃើញ អៀង ធីរិទ្ធ មកមន្ទីរពេទ្យព្រះកេតុមាលាពីរបីដង។ តើក្រៅពីឈ្មោះ អៀង ធីរិទ្ធ ហ្នឹងលោកមានស្គាល់មេដឹកនាំខ្មែរក្រហមជំនាន់ហ្នឹងថ្នាក់ដឹកនាំប្រទេសណាមួយដែរទេ?

**ឆ៖** ជំនាន់ហ្នឹងខ្ញុំស្គាល់តែលោកស្រី អៀង ធីរិទ្ធ ទេព្រោះលោកស្រី អៀង ធីរិទ្ធ ហ្នឹងខ្ញុំឧស្សាហ៍ឃើញ តែបើមេដឹកនាំនានា ដូចជាលោក ខៀវ សំផន, លោក នួន ជា ក៏ខ្ញុំអត់ដែលឃើញទេ ឮតែឈ្មោះ។

[០៩:៣៥:៥៦]

**ស៖** អ៊ីចឹងនៅពេលដែលប្រជុំ លោកមានប្រសាសន៍ថា ប្រជុំ៣ថ្ងៃហ្នឹង តើមានដែលឃើញ លោក ខៀវ សំផន ឬក៏លោក នួន ជា ហ្នឹងគាត់ចូលមកក្នុងការប្រជុំទីនោះដែរទេ?

**ឆ៖** ពេលហ្នឹង អត់ឃើញគាត់ទេ ឃើញតែមេធំៗ ដែលនៅក្តាប់ខ្ញុំហ្នឹង ព្រោះអត់ដែលឃើញ មុខគាត់របៀបម៉េចផង។

**ស៖** បាទ សូមអរគុណ។ សំណួរខ្ញុំលោតមកខាងរឿងការចាប់វិញម្តង។ ដោយសារលោកបាន ជម្រាបជូនព្រះរាជអាជ្ញាម្សិលមិញច្រើនហើយ ទាក់ទងនឹងប្រជុំហើយ មានការចាប់ខ្លួន។ នៅក្នុងការ សម្ភាសរបស់លោកនៅក្នុងឯកសារដដែល និយាយអំពីឆ្នាំ៧៦ ដែលខ្ញុំជម្រាបជូនអម្បាញ់មិញហ្នឹង។ តើ ក្នុងឆ្នាំ៧៦ តាំងពីដើមឆ្នាំរហូតដល់ពេលគេបញ្ជូនលោកមកខេត្តកំពង់ឆ្នាំង ចន្លោះហ្នឹង គេចាប់ជាបន្ត បន្ទាប់រហូតដល់បញ្ជូនលោកមកកំពង់ឆ្នាំងដែរឬទេ?

**ឆ៖** ពេលនុ៎ងគេចាប់បង យៀត មុនដែលមេខ្ញុំហ្នឹង រួចទៅបានគេបញ្ជូនខ្ញុំទៅកំពង់ឆ្នាំងហ្នឹង ហើយនៅក្នុងវរៈខ្ញុំហ្នឹង គេផ្លាស់បន្តៗ មិនដឹងគេទៅខាងណាទេ ព្រោះក្នុងពេលហ្នឹង វាអត់មានពីណា នៅក្នុងវរៈហ្នឹងទៀតទេ ព្រោះបាត់បន្តៗ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឆ្លងចូលមកទាក់ទងជាមួយនឹងការដ្ឋានធ្វើព្រលានយន្តហោះ ខេត្តកំពង់ឆ្នាំងបន្តិច។ លោកបានជម្រាបជូនអង្គសវនាការច្រើនហើយ ទាក់ទងជាមួយនឹងលក្ខខណ្ឌនៃ ការការធ្វើការងារ។ សំណួរខ្ញុំសួរទាក់ទងជាមួយនឹងទីកន្លែងរស់នៅ ដែលលោកបាននិយាយអំពី លក្ខខណ្ឌធ្វើការងារទាំងការធ្វើពេលព្រឹក ពេលថ្ងៃ ពេលយប់ ឬរបបអាហារជាដើម ប៉ុន្តែទីកន្លែងស្នាក់ នៅវិញ តើលោកអាចជម្រាបអង្គសវនាការបានទេ ថាតើគេធ្វើជាផ្ទះ ឬជារោងត្រឹមត្រូវឲ្យសម្រាក ឲ្យ ដេកពួនដែរឬទេ?

[០៩:៣៨:១៤]

**ឆ៖** រោងជំនាន់នុ៎ង គេធ្វើរោងវែងជាប់គ្នា រោងប្រក់ស្បូវ ឲ្យសម្រាកតាមរោងហ្នឹង ដូចគេធ្វើ ខណ្ឌ មួយខណ្ឌ មួយខណ្ឌហ្នឹង។ បើពួកពលករហ្នឹង គេធ្វើដាក់កម្រាលឲ្យដេកជាមួយគ្នា បន្តៗគ្នា។

**ស៖** ចុះទឹកប្រើប្រាស់ ទឹកហូបក៏ដោយ ទឹកងូតក៏ដោយ ឬក៏កន្លែងអនាម័យ បង្គន់ជាដើម គេ មានធ្វើឲ្យគ្រប់គ្រាន់ដែរទេ?

**ឆ៖** ពេលហ្នឹងទឹកងូត បើទឹកផឹកបានហូបគ្រប់គ្រាន់ បើទឹកងូត អត់បានគ្រប់គ្រាន់ទេ ព្រោះ ពេលនុ៎ង ព្រោះការងារវា គេធ្វើការមិនសូវបានឈប់ មិនសូវបានមានការងូតទឹកទេ ព្រោះជួនកាលអត់

ទឹក២ថ្ងៃ ជួនកាល៣ថ្ងៃ ព្រោះការងារគេសកម្ម គេឲ្យលត់ដំ។

**ស៖** បាទ សូមអរគុណ។ លោកនិយាយអំពីការបំបែកថ្ម ឬការផ្ទុះឆ្អូនថ្ម យកថ្មទៅធ្វើព្រលានយន្តហោះកំពង់ឆ្នាំង។ អម្បាញ់មិញ លោកបាននិយាយអំពីអ្នករបួស ដែលដឹកទៅកំពង់ឆ្នាំង ដែលថារបួសធ្ងន់ស្រាលយ៉ាងម៉េចនោះ។ សំណួរខ្ញុំចង់សួរថាតើនៅក្នុងការដ្ឋានហ្នឹង គេមានឲ្យមានពេទ្យនៅតាមមើល ឬក៏តាមព្យាបាលអ្នកដែលនៅកំពុងធ្វើការនៅកន្លែងហ្នឹងដែរទេ?

**ឆ៖** នៅកន្លែងនុំងមានពេទ្យដែរ គេគ្រាន់តែថារុំរបួស រួចទៅគេបញ្ជូនមកមន្ទីរពេទ្យកំពង់ឆ្នាំងហើយ ព្រោះពេទ្យនៅកន្លែងនុំង គេគ្រាន់តែថាមួយជួយឲ្យរបួសហ្នឹងមានការធូរស្រាលបន្តិច គេនឹងបញ្ជូនមកកំពង់ឆ្នាំង។

[០៩:៤០:០៨]

**ស៖** បាទ សូមអរគុណ។ ចុះចំពោះអ្នកដែលមានជំងឺ តើនៅពេលដែលធ្វើការហ្នឹង មានជាគ្រុនក្ដៅ ឬក៏គ្រុនចាញ់ រាករូសអីមានដែរទេ ក្នុងពលករធ្វើការហ្នឹង?

**ឆ៖** ពេលនុំងមានដែរ តែពេទ្យហ្នឹង នៅកន្លែងនុំង គេមានថ្នាំសង្កូវតិចតួច អ៊ីចឹងព្យាបាលបានតែបន្តិចបន្តួចទេ តែការធំដុំ គេយកមកកំពង់ឆ្នាំងទេ។

**ស៖** បើមានពលករឈឺនៅក្នុងក្រុមរបស់លោកជាដើម តើគេឲ្យឈប់សម្រាកទេ?

**ឆ៖** ពេលឈឺហ្នឹង គេពិនិត្យយើងត្រឹមត្រូវ គេឲ្យពេទ្យពិនិត្យ គេខ្លាចយើង ថាយើងហ្នឹងធ្វើពុតខ្ជិលការងារ។ អ៊ីចឹងឈឺល្មមៗមិនសូវប៉ានឈប់ទេ ទៅធ្វើហើយ ព្រោះខ្លាចគេថា យើងហ្នឹងពុត ក្ដៅខ្លួនបន្តិចបន្តួច ឬមួយក៏ហេវហត់ម៉េចទៅទាំងអ៊ីចឹង ព្រោះអត់សូវប៉ានឈប់ទេ ព្រោះកន្លែងហ្នឹងការលុតដំ។

**ស៖** តើការពិនិត្យ ពាក្យថា ការពិនិត្យ ការមើលរបស់គេឈឺ មិនឈឺហ្នឹង តើគេយកមូលដ្ឋាន ឬក៏មានអ្វី ដែលមកពិនិត្យថា ឈ្មោះមិត្តណាមួយឈឺ ឬមិនឈឺ? ក្នុងនាមលោកជាពេទ្យដែរ តើលោកសម្គាល់យ៉ាងម៉េចទៅ?

**ឆ៖** គេមកពិនិត្យហ្នឹង គេដាក់*តែអាតូ* ហើយនិងគេដាក់ការនេះ ប្រដាប់ស្ទង់ ដើម្បីគេថា មើលទៅបើយើងក្ដៅ អាហ្នឹងគេឲ្យថ្នាំប៉ារ៉ាលេបទៅ។ បើក្ដៅខ្លាំង ក៏គេថា នឹងឲ្យយើងសម្រាកសិន បន្តិចបន្តួច។ បើជួនកាលគេថា អ្ហេ! ក្ដៅហើយនៅធ្វើបាន គេឲ្យទៅទៀត។

[០៩:៤២:១០]

**ស៖** នៅក្នុងអង្គភាពរបស់លោកមានអ្នកឈឺស្លាប់នៅនឹងកន្លែងដែរទេ?

**ឆ៖** ពេលនុ៎ងមានអ្នកធ្វើជាមួយខ្ញុំ មានដួលនៅនឹងកន្លែងដែរ តែគេយកទៅមន្ទីរពេទ្យ មិនដឹងជាស្លាប់ ឬរស់ទេ ព្រោះពេលធ្វើហ្នឹង ធ្វើដោយមនុស្សអត់មានកម្លាំង គឺសុទ្ធតែអ្នកស្គមៗ ព្រោះគេបញ្ជូនទៅពេទ្យកំពង់ឆ្នាំងហើយ។

**ស៖** បាទ សូមបន្តសំណួរទាក់ទងជាមួយនឹងចម្លើយរបស់លោក ដែលនិយាយអំពីការដកមនុស្សទៅបាត់ ទៅបាត់។ ខ្ញុំសូមលើកនៅក្នុងឯកសារដដែលគឺ E3/7537, ERN ជាភាសាខ្មែរ 00019648, ERN ជាភាសាអង់គ្លេស 251256។ ទាក់ទងជាមួយនឹងការដកមនុស្សទៅបាត់ ទៅបាត់ តើលោកដឹងទេថា ការដកមនុស្សនេះ គេដកមនុស្សយកទៅណាទេ?

**ឆ៖** ពេលនុ៎ងខ្ញុំអត់ដឹងដែរ ព្រោះគិតតែពលកម្មខ្លួនឯង ខ្លាចជីវិតស្លាប់ដែរ ព្រោះគេថា ខ្ញុំជាអ្នកទោសហើយ អ៊ីចឹងគិតតែប្រឹងខ្លួនឯង។ ខ្លួនឯងឲ្យបានរស់ដែរ ត្រង់ជីវិតគេ ខ្ញុំក៏អត់ហ៊ានសួរដែរ ព្រោះជំនាន់នុ៎ង គេអង្គការភ្នែកម្នាស់ គឺអត់មានទៅឲ្យដឹងរឿងទេ។

**ស៖** បាទ តាមការមើលឃើញដោយផ្ទាល់របស់លោកនៅក្នុងការដ្ឋានវែថ្ម ឬក៏ធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំងកាលនោះ តើលោកមើលឃើញចំនួនជាសរុបមនុស្សស្រី និងមនុស្សប្រុស តើមនុស្សស្រី និងប្រុសអ្នកណាច្រើនជាងអ្នកណា?

**ឆ៖** បាទ នៅកន្លែងនុ៎ង អត់មានមនុស្សស្រីទេ សុទ្ធតែមនុស្សប្រុស កន្លែងនុ៎ង។

**ស៖** ចុះមានពួកកុមារនៅធ្វើការជិតៗ នៅក្នុងការដ្ឋាន ប៉ុន្តែកងផ្សេងគ្នាមានដែរទេ?

[០៩:៤៤:២៤]

**ឆ៖** កុមារក៏អត់ឃើញដែរ ច្រើនតែពួកយោធាដែលមានអាយុចាប់ពីប្រាំប្រាំបីដណ្ដប់ឡើងទៅដូចជាខ្ញុំអ៊ីអ៊ីចឹង។

**ស៖** លោកនៅធ្វើការព្រលានយន្តហោះហ្នឹង តើក្នុងចំណោម -- ក្នុងអំឡុង៣ខែហ្នឹង លោកដែលឮ ឬក៏ដែលឃើញថ្នាក់ដឹកនាំលើការដ្ឋានហ្នឹងទៅពិនិត្យ ឬក៏ទៅទស្សនកិច្ចនៅព្រលានយន្តហោះហ្នឹងដែរឬទេ?

**ឆ៖** បាទ ឃើញដែរ ឃើញគេដើរជាមួយចិន និងកូរ៉េ តែខ្ញុំអត់ស្គាល់គេ មិនដឹងមេថ្នាក់ណាថ្នាក់ណា ឃើញតែគេដើរជាមួយចិន និងកូរ៉េ គេដើរពិនិត្យហ្នឹង។

**ស៖** ខ្ញុំសួរអំពីការឮ ឬការដឹង មិនថាឃើញទេ។ នៅក្នុងពេលដែលកំពុងធ្វើការ លោកដែលឮ

សួរឈ្មោះ មាស មុត ឬ ស៊ូ ម៉េត ដែរទេ?

**ឆ៖** ពេលនុំងអត់បានដឹងដែរទេ ព្រោះអត់បានប៊ានសួរគ្នា ព្រោះពេលនុំង ពេលធ្វើការយើងមិនអាចគេឲ្យនិយាយស្ដីអីទេ ព្រោះមកដល់កន្លែង គិតតែរៀងខ្លួន ខ្លាចដល់ពេលម៉ោង ទៅធ្វើការទៀត។

**ស៖** អំពីការប្រជុំ តើការប្រជុំជីវភាព ឬក៏ប្រជុំក្រុម ប្រជុំកង ណែនាំរបស់ថ្នាក់ដឹកនាំក្រុមរបស់លោក មានការប្រជុំជាប្រចាំរាល់ថ្ងៃ ឬរាល់សប្ដាហ៍ដែរទេ ក្រោយពេលការងាររបស់លោក?

**ឆ៖** ពេលប្រជុំ រយៈកាល៣ថ្ងៃគេប្រជុំម្ដង រយៈកាល៣ថ្ងៃគេប្រជុំម្ដង ធ្វើការហ្នឹង។

**ស៖** បាទ ក្រោយមានការប្រជុំខ្លះៗអ៊ីចឹង តើនៅពេលយប់ ខ្ញុំមិនសួរពេលថ្ងៃទេ ពេលយប់ តើមានដែលអង្គការ ឬក៏មេៗនៅក្នុងការគ្រប់គ្រងហ្នឹងដកមនុស្ស ឬមកហៅមនុស្សចេញពីកង ពីក្រុមរបស់លោកទាំងយប់ដែរទេ?

[០៩:៤៦:៣៧]

**ឆ៖** ពេលនុំងធ្វើការហ្នឹង មានដែរ តែគេគ្រាន់តែថា មិត្តឯងផ្លាស់ពីកន្លែងនេះ ទៅកន្លែងនោះ តែត្រង់គេយកទៅណា ខ្ញុំអត់ដឹងដែរទេ។

**ស៖** សំណួរខ្ញុំចង់ពេលយប់ មានទេ មានដកទាំងយប់ទេ?

**ឆ៖** នៅពេលនុំង យប់អត់មានទេ មានតែពេលថ្ងៃ គេផ្លាស់ទៅ ដូចថា ព្រឹកឡើង ឬល្ងាច គេថា មិត្តឯងផ្លាស់ទីនេះ ផ្លាស់ទីនោះ។

**ស៖** ជាសំណួរចុងក្រោយ។ តើកងរបស់លោកដែលដកចេញទៅជាមួយគ្នាហ្នឹង មកដល់ក្រោយថ្ងៃ០៧ មករា ១៩៧៩ តើលោកបានឃើញពួកគេវិលត្រឡប់មកផ្ទះវិញដែរទេ?

**ឆ៖** ពេលនុំង ស្រុកនៅឆ្ងាយពីគ្នា ហើយខ្ញុំក៏អត់ដែលបានឃើញគេ គេអត់បានដែលឃើញខ្ញុំ ព្រោះដើរទៅ ជំនាន់នុំង មក៧៩នុំង អត់ដែលជួបគ្នាទេ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមអរគុណលោកសាក្សី។ ខ្ញុំបាទសុំអស់សំណួរត្រឹមនេះ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[០៩:៤៨:១៣]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិ ការពារក្តីលោក ខៀវ សំផន ជាមួយនឹងលោកមេធាវី គង់ សំអុន។ ខ្ញុំមានសំណួរសួរបន្តទៅនឹងសក្ខីកម្មរបស់លោកមួយចំនួនតូចទេ ខ្ញុំមិនសួរអ្វីវែងឆ្ងាយប៉ុន្មានទេ។ ខ្ញុំនឹងផ្តោតជាសំខាន់ទៅលើពេលដែលលោកធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ លោកបានឆ្លើយថា លោកនៅធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងអស់រយៈពេល៣ខែ។ អ៊ីចឹងខ្ញុំចង់ដឹងថាការដ្ឋានហ្នឹង គេសាងសង់ព្រលានយន្តហោះស៊ីវិល ឬក៏យោធា?

**លោក នួន ត្រិច៖**

**ឆ៖** ពេលនុ៎ង ខ្ញុំអត់ដឹងដែរទេ ព្រោះគេឲ្យទៅលត់ដំកន្លែងនុ៎ង មិនដឹងជាព្រលានយន្តហោះស៊ីវិល ឬយោធាទេ ព្រោះគេថា សាងសង់ហ្នឹងសម្រាប់ដាក់កប៉ាល់ហោះ សម្រាប់តែកប៉ាល់ហោះចម្បាំង។

**ស៖** អ៊ីចឹងលោកដឹងថា គេដាក់យន្តហោះចម្បាំងដែរ។ លោកដឹងព័ត៌មាននេះមកពីណា?

[០៩:៤៩:៣៨]

**ឆ៖** ព្រោះពេលនុ៎ងគេ ខ្ញុំផ្លាស់ទៅ គេដកទៅកន្លែងនុ៎ង គេថាធ្វើហ្នឹង គេថា មេនៅកន្លែងនុ៎ងគេថា យើងប្រឹងធ្វើ ព្រោះព្រលានយន្តហោះហ្នឹង ធ្វើឲ្យមាំទាំ ព្រោះកន្លែងហ្នឹងជាព្រលានយន្តហោះចម្បាំងសម្រាប់ធ្វើ ឲ្យធំសម្រាប់កប៉ាល់ហោះធំៗចុះ។

**ស៖** លោកបាននិយាយអំពីមេរបស់លោក អ៊ីចឹងលោកដឹងទេថា មេរបស់លោកជាស៊ីវិល ឬក៏ជាយោធា?

**ឆ៖** មេរបស់ខ្ញុំហ្នឹង អត់មានស៊ីវិលទេ សុទ្ធតែជាយោធាទេ។

**ស៖** លោកក៏បានឆ្លើយផងដែរថា នៅព្រលានយន្តហោះកំពង់ឆ្នាំង លោកធ្វើការជាមួយអ្នកដែលមកពីវរសេនាតូចរបស់លោក ហើយលោកស្គាល់គ្នា ក៏ប៉ុន្តែលោកនិយាយផងដែរ ថាមានអ្នកមកពីកងវរសេនាធំផ្សេង ដែលលោកមិនស្គាល់ផងដែរ។ អ៊ីចឹងលោកចាំ ឬក៏លោកដឹងថា តើអ្នកទាំងអស់

ហ្នឹង មកពីវរសេនាធំណា ឬក៏កងពលណាដែរ<បើលោកមិនចាំឈ្មោះបុគ្គលម្នាក់ៗនោះ>?

**ឆ៖** កន្លែងហ្នឹង វាកន្លែងចម្រុះកងពល កងពល ព្រោះកងពលហ្នឹង មានកងពលខាងកងពល ៣១០ និងកងពលគេនានា ព្រោះចម្រុះកងពល ឲ្យតែជាប់និន្នាការ គេហៅថា ពួកដែលជាប់និន្នាការខាងនយោបាយ គឺថាខ្មាំង។

**សៈ** ក្រៅពីកងពល៣១០ហ្នឹង លោកដឹងថា អ្នកទាំងអស់ហ្នឹងមកពីកងវរសេនាតូចណា កងវរសេនាធំណា កងពលធំណាផ្សេងទៀតទេ?

**ឆ៖** ព្រោះពេលនុ៎ង ខ្ញុំអត់ស្គាល់ដែរ ព្រោះពេលនុ៎ង សុទ្ធតែគេមកគ្រប់ចម្រុះកងវរសេនាធំ ព្រោះទៅធ្វើកន្លែងនុ៎ង គិតតែពីរឿងប្រឹងរៀងខ្លួន ដើម្បីរស់។

[០៩:៥២:២៧]

**សៈ** លោកបាននិយាយថា លោកបានធ្វើការនៅជាប់នឹងអ្នក<ជំនាញម្នាក់ខាង>បំផ្ទុះឆ្អួន។ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកធ្វើការនៅក្បែរលោកហ្នឹង មកពីកងពល<ជាមួយលោក> ឬក៏មកពីកន្លែងណាផ្សេង?

**ឆ៖** អ្នកមកធ្វើការនុ៎ង សុទ្ធតែមកពីកងពល។ តែកងពលហ្នឹង វានៅក្នុងវរសេនាធំ ឬវរសេនាតូច តែវានៅបែកៗគ្នា ព្រោះអត់ស្គាល់ទេ សុទ្ធតែអ្នកទោសដូចគ្នា។

**សៈ** ចំពោះអ្នកដាក់ឆ្អួនបំផ្ទុះថ្មហ្នឹង លោកដឹងថា ពួកគេទទួលការបង្រៀនពីណាទេ? <តើការបង្រៀននោះគឺបានមកពី>អ្នកបច្ចេកទេសចិន<ដែលលោកបានលើកឡើងឬ? តើអ្នកបច្ចេកទេសចិនទាំងនោះជាអ្នក>បង្រៀនអ្នកទាំងអស់ហ្នឹង ឲ្យបំផ្ទុះថ្មហ្នឹងទេ ឬក៏ពួកគាត់ធ្លាប់រៀនមកតាំងពីមុនហ្នឹងមកទៀត?

**ឆ៖** ពេលនុ៎ងខ្ញុំអត់ដឹងដែរ ព្រោះឃើញតៗគ្នា ឃើញតែដុតហ្នឹង តែខ្ញុំអត់ដឹងថា អ្នកណាជាអ្នកបង្រៀនបន្តទេ ព្រោះខ្ញុំទៅឃើញតែគេដុតបន្តគ្នា។

**សៈ** ឥឡូវនេះខ្ញុំចង់ត្រឡប់ក្រោយបន្តិច ពាក់ព័ន្ធនឹងអ្វីដែលសហព្រះរាជអាជ្ញាបានសួរលោក គឺគាត់បានដកស្រង់ប្រតិចារឹកមួយនៃខ្សែអាត់ស្តាប់សំឡេងរបស់លោក ដែលបានផ្តល់ចម្លើយជូនសហចៅក្រមស៊ើបអង្កេត។ ខ្ញុំនឹងផ្តល់លេខយោងពិតប្រាកដជូនអង្គជំនុំជម្រះ និងភាគី។ គឺមានលេខ E3/7877.1, ERN ជាភាសាបារាំង 01358654, ជាភាសាខ្មែរគឺ <01357613> យើងអត់ទាន់មានជាភាសាអង់គ្លេសទេ។ <ប៉ុន្តែមានយោងទៅលើពេលវេលា ហើយនិងមាន>ប្រតិចារឹក<នៃឯកសារ

សំឡេង> លេខ D231/24R គឺជាប្រតិចារឹកដោយផ្នែក <នៅចន្លោះពេល ០០:៥៨:៤៥ និង ០០:៥៩:៣១>។ ពេលនោះគឺគេសួរលោកច្បាស់ដោយអ្នកស៊ើបអង្កេត។ ពេលគេសួរថា៖ "តើអ្នកដែលរបួសពីការផ្ទុះហ្នឹងស្លាប់ទេ? លោកឆ្លើយថា៖ មិនដែលមានអ្នកស្លាប់ទេ គឺគ្រាន់តែមានអ្នករបួសធ្ងន់តែប៉ុណ្ណោះ។ ហើយបន្ទាប់មកលោកបានបញ្ជាក់ថា អ្នកដែលរបួសធ្ងន់ហ្នឹងត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ។"

ពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ព្រះរាជអាជ្ញា លោកបានឆ្លើយថា អ្នកទាំងអស់ហ្នឹងគឺគេបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំង គឺលោកឆ្លើយមុនហ្នឹង។ សូមទោស គឺមិនមែនព្រលានយន្តហោះកំពង់ឆ្នាំងទេ គឺមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។ អ៊ីចឹងលោកដឹងថា តើមន្ទីរពេទ្យហ្នឹងគ្រប់គ្រងដោយពួកយោធា ឬក៏ដោយជនស៊ីវិល? លោកដឹងទេ អ្នកណាជាអ្នកគ្រប់គ្រងត្រួតត្រាលើមន្ទីរពេទ្យហ្នឹង?

**ឆ៖** ក្នុងមន្ទីរពេទ្យហ្នឹងគ្រប់គ្រងដោយភូមិភាគ៥០២ ជាកងពលខាង មកខាងនិរតី។

**ស៖** អ៊ីចឹងគឺមន្ទីរពេទ្យហ្នឹងជាមន្ទីរពេទ្យយោធា តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលហ្នឹងមន្ទីរពេទ្យហ្នឹងជាមន្ទីរពេទ្យយោធា ព្រោះគេសម្រាប់ព្យាបាលអ្នកដែលធ្វើការពលករ ដែលមានទោសកំហុសនៅកន្លែងព្រលានយន្តហោះកំពង់ឆ្នាំង។

[០៩:៥៧:២៨]

**ស៖** អ៊ីចឹងលោកខ្លួនឯងផ្ទាល់លោកធ្លាប់ទៅមន្ទីរពេទ្យហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ទៅសម្រាកដែរ។ ព្រោះពេលហ្នឹងខ្ញុំហត់ហេវ ហើយមានជំងឺគ្រុនចាញ់រើឡើង ក៏គេបញ្ជូនទៅដេកកន្លែងនុ៎ង។

**ស៖** បើយោងតាមការរៀបរាប់របស់លោកកាលពីមុន <ខ្ញុំគិត>ថា លោក<បាន>ទៅមន្ទីរពេទ្យ<នោះ>ក្រោយពីគេព្យាបាលលោក ពិនិត្យលោកហើយនៅការដ្ឋានកំពង់ឆ្នាំងហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ ព្រោះគេបញ្ជូនទៅមន្ទីរពេទ្យកំពង់ឆ្នាំងហ្នឹងដែរ។

**ស៖** មុននេះលោកថាមន្ទីរពេទ្យហ្នឹង គឺសម្រាប់តែទទួលអ្នកជំងឺដែលមកពីការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងតែប៉ុណ្ណោះ។ អ៊ីចឹងក្នុងចំណោមអ្នកជំងឺនៅមន្ទីរពេទ្យហ្នឹង គឺសុទ្ធតែជាអ្នកមកពីការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងទាំងអស់មែនទេ?

**ឆ៖** មន្ទីរពេទ្យហ្នឹង គេសម្រាប់តែព្យាបាលពួកព្រលានយន្តហោះដែលធ្វើការព្រលានយន្តហោះ

ហ្នឹងទាំងអស់ ឲ្យតែមានឈឺគឺយកមកដាក់កន្លែងហ្នឹងហើយ។

**ស៖** សូមអរគុណ។ លោកផ្ទាល់លោកធ្លាប់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យហ្នឹង។ អ៊ីចឹងលោកមាននឹកឃើញទេ ថាគេបញ្ជូនលោកទៅយ៉ាងម៉េច? មានអង្គភាពពិសេសណាមួយសម្រាប់ដឹកអ្នកជំងឺទៅមន្ទីរពេទ្យហ្នឹងទេ? លោកចាំទេ ពេលដែលគេដឹកលោកទៅហ្នឹង គេធ្វើយ៉ាងម៉េច?

[០៩:៥៩:៤៣]

**ឆ៖** ពេលដឹកទៅហ្នឹង គេឲ្យខ្ញុំហ្នឹង គេមានឡានមួយឡានកូរ៉េ កាលណាមានអ្នកឈឺពីពេទ្យយើងនៅកន្លែងព្រលានហ្នឹង គេថាអ្នកហ្នឹងឈឺធ្ងន់ គេឲ្យដឹកឡានហ្នឹងយកទៅដាក់មន្ទីរពេទ្យនៅៗប្រចាំនៅខេត្តកំពង់ឆ្នាំងហ្នឹង។

**ស៖** ខ្ញុំឈប់សួរអំពីមន្ទីរពេទ្យហើយ អ៊ីចឹងខ្ញុំចូលទៅនិយាយអំពីការងាររបស់លោកនៅព្រលានយន្តហោះកំពង់ឆ្នាំង ជាពិសេសពាក់ព័ន្ធនឹងរបបអាហារ។ សំណួរដំបូងត្រង់ចំណុចនេះ លោកបាននិយាយអំពីការងាររបស់លោកជាមួយអ្នកបំផ្ទុះថ្មដើម្បីយកថ្ម ហើយលោកក៏បាននិយាយអំពីអ្នកដែលទទួលបន្ទុកខាងដឹកជញ្ជូនថ្មទៅសាងសង់ផ្លូវយន្តហោះ។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកទាំងអស់គ្នាហ្នឹងនៅក្នុងកងតែមួយ <ឬ>មានកង<មួយ សម្រាប់>អ្នក<ដឹកដី និងបំផ្ទុះថ្ម ហើយមានកងមួយផ្សេងទៀតសម្រាប់>ដឹកថ្មទៅសាងសង់ផ្លូវព្រលានយន្តហោះហ្នឹង? មានកងផ្សេងៗគ្នា ឬក៏លោកទាំងអស់គ្នាធ្វើការហ្នឹងនៅក្នុងតែកងតែមួយទេ?

**ឆ៖** កន្លែងនុ៎ងគេចែកជាក្រុមៗ វាចម្រុះ ព្រោះគេ តាមគេចាត់តាំង។ ជួនកាលគេឲ្យទៅខាងដឹកដី ជួនកាលគេឲ្យទៅខាងដឹកដាប់ថ្ម ព្រោះអត់មានប្រកាន់ថា អ្នកហ្នឹងទៅខាងដឹកដីតែមួយមុខទេ ព្រោះអាហ្នឹងតាមគេចាត់តាំង។

**ស៖** ពាក់ព័ន្ធនឹងការហូបចុក លោកហូបតែជាមួយក្រុមរបស់លោក ឬក៏លោកហូបរួមគ្នាជាមួយបុគ្គលិកទាំងអស់ដែលធ្វើការនៅកន្លែងហ្នឹង?

**ឆ៖** ពេលនុ៎ងពេលម៉ោងឈប់ហ្នឹងហូបតាមក្រុម ព្រោះហូបបាយតាមក្រុម អត់មានទៅជាមួយគ្នាទាំងអស់ទេ ព្រោះតាមក្រុម ដល់ឈប់ពេលម៉ោងសម្រាក គឺតាមក្រុម ទៅតាមក្រុម។

[១០:០២:២១]

**ស៖** អ៊ីចឹងពាក់ព័ន្ធនឹងរបបអាហារ និងចំនួនពេលហូបចុកហ្នឹង គឺលោកដឹងតែពាក់ព័ន្ធនឹងក្រុមរបស់លោកតែប៉ុណ្ណោះ មែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆះ** បាទ ពេលនុ៎ងដឹងតែតាមក្រុមរបស់ខ្ញុំទេ ព្រោះនៅក្រុមគេយើងមិនអាចដើរទៅអើតមើលក្រុមគេបានទេ ព្រោះជំនាន់នុ៎ងគឺថា អត់មានដើរទៅលេងគ្នាបានទេ។

**សះ** លោកបានឆ្លើយថា លោកបានចេញពីព្រលានយន្តហោះកំពង់ឆ្នាំង ហើយគេចាត់ឲ្យលោកទៅខាងព្យាបាលវិញ ខាងពេទ្យវិញ។ នេះជាអ្វីដែលខ្ញុំយល់ ដោយសារតែពេលនុ៎ងមានការវាយប្រហារពីសំណាក់កងទ័ពវៀតណាមចូលមកនៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងលោកអាចកំណត់ពេលវេលាឲ្យបានច្បាស់ទេថា ពេលណាដែលគេបញ្ជូនឲ្យលោកទៅខាងពេទ្យវិញនោះ?

**ឆះ** ពេលនុ៎ងនៅចូលឆ្នាំ៧៨ គេត្រូវថាកងទ័ពវៀតណាមចូលវ៉ៃលុកនៅក្នុងប្រទេសកម្ពុជា ហើយអ្នកទោសទាំងប៉ុន្មាននៅក្នុងព្រលានយន្តហោះហ្នឹង គេថាអ្នកអស់ហ្នឹងសុទ្ធតែរួចពីទោសហើយ អ៊ីចឹងត្រូវទៅទប់ទល់នឹងវៀតណាមចូលឈ្លានពានប្រទេសកម្ពុជា។

**សះ** លោកនិយាយថា នៅឆ្នាំ១៩៧៨ លោកអាចចាំឲ្យច្បាស់ជាងហ្នឹងបន្តិចបានទេ ដើមឆ្នាំ ពាក់កណ្ដាលឆ្នាំ ឬក៏ចុងឆ្នាំ៧៨? ហើយរដូវ បើនិយាយពីរដូវវិញ រដូវណា? រដូវប្រាំង ឬក៏រដូវវស្សា?

**ឆះ** ពេលទៅនុ៎ងវារដូវទឹកលិច ទឹកធំ វីកហ្នឹងនៅឆ្នាំ១៩៧៨ហ្នឹង គឺទឹកធំលិចទាំងភ្នំពេញទាំងអី រឿងនៅពេលនុ៎ងជារដូវបែបខែវស្សា ព្រោះទឹកលិចខ្លាំង។

[១០:០៤:៥៧]

**សះ** ពេលលោកនៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង លោកដឹងយ៉ាងម៉េចថា លោកត្រូវបានគេបញ្ជូនឲ្យទៅធ្វើពេទ្យវិញ? អ្នកណាមកប្រាប់លោកថា លោកត្រូវទៅធ្វើពេទ្យហ្នឹង? គេកោះប្រជុំលោក ហើយគេប្រាប់លោក ឬក៏យ៉ាងម៉េចពេលនុ៎ង?

**ឆះ** ពេលនុ៎ង គេឲ្យដកពីកំពង់ឆ្នាំងមកនៅនឹងសាលាមហាវិទ្យាល័យនៅតាខ្មៅ ជិតផ្សារតាខ្មៅ ហើយគេថា នឹងបញ្ជូនទៅនៅខាង វ៉ៃខាងមេមត់ ព្រោះខាងនុ៎ង កងទ័ពវៀតណាមវ៉ៃខ្លាំង បុកខាងនុ៎ងហើយ។ អ៊ីចឹងដល់បញ្ជូនទៅ ជិះអាម៉ារីនទៅឡើងទន្លេបិទ ក៏គេបញ្ជូនទៅដល់កន្លែងស្នួល គេក៏គេចាត់តាំងឲ្យខ្ញុំជាពេទ្យតាមកងទ័ពវិញ។

**សះ** អ៊ីចឹងខ្ញុំចង់សួរថា គេដកលោក ហើយគេប្រាប់លោកថា លោកត្រូវចេញទៅធ្វើពេទ្យ។ អ៊ីចឹងមុនពេលចាកចេញទៅនោះ មានក្រុមទាហានផ្សេងទៀតដែលត្រូវបានគេដក ហើយបញ្ជូនទៅកន្លែងផ្សេងទៀត ដូចលោកដែរទេ? លោកដឹងទេ?

**ឆះ** ពេលនុ៎ង ដកទៅច្រើន តែខ្ញុំអត់ស្គាល់គេដែរ ព្រោះដកទៅនៅនឹងសាលាតាខ្មៅនុ៎ង ព្រោះ

បញ្ជូនខ្ញុំទៅកន្លែងនុ៎ង។

[១០:០៦:៥២]

**ស៖** ពេលថា លោកថានៅសាលាតាខ្មៅហ្នឹង មានមនុស្សច្រើនហ្នឹង លោកឃើញផ្ទាល់នៅកន្លែងហ្នឹង <គឺឃើញអ្នកទាំងអស់ហ្នឹងម្តងទៀត ដែលលោកបានឃើញពួកគាត់នៅកន្លែង ដែលគេចាត់តាំងឲ្យលោកទៅកាន់អង្គភាពពេទ្យហ្នឹង ឬ? តើលោកបាន>ឃើញមានអ្នកណាផ្សេង<ទៀត ដែលមិនមែន>នៅក្នុងកងវរសេនាតូចជាមួយលោក<ទេ ប៉ុន្តែកាលពីមុនហ្នឹង អ្នកទាំងអស់ហ្នឹងធ្វើការនៅ>ព្រលានយន្តហោះកំពង់ឆ្នាំង <ហើយត្រូវបានគេបញ្ជូនមកនៅក្នុងសាលាហ្នឹងដូចលោកដែរ>?

**ឆ៖** ពេលនុ៎ងអ្នកមកពីព្រលានយន្តហោះជាមួយខ្ញុំហ្នឹងមកច្រើន មកនៅនឹងសាលាតាខ្មៅហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ លោកមេធាវី គង់ សំអុន មិនមានសំណួរទេ លោកប្រធាន អ៊ីចឹងយើងខ្ញុំសូមចប់ត្រឹមហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អង្គជំនុំជម្រះអរគុណលោក នួន ត្រិច សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី ដល់ពេលនេះ បានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលកាន់ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ក្នុងការជូនលោក នួន ត្រិច វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ សូមលោក នួន ត្រិច ចាកចេញ អញ្ជើញចាកចេញទៅចុះ!

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១០:០៨:៤៧]

បាទ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះមានបំណងស្តាប់សារណាផ្ទាល់មាត់របស់ភាគី លើបញ្ហាចំនួនពីរ។ ទី១ គឺពាក់ព័ន្ធទៅនឹងការឯកសារភស្តុតាង អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពាក់ព័ន្ធទៅនឹងអ្នកជំនាញ ដែលមានរហស្សនាម 2-TCE-1062។ ហើយបញ្ហាទី២ ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (2-TCCP-237) ដែលគាត់បានមកផ្តល់សក្ខីកម្មរួចហើយ ហើយគាត់បានលះបង់ការផ្តល់សក្ខីកម្មពាក់កណ្តាលទី។

បាទ ហើយឥឡូវនេះ យើងចូលពិភាក្សាបញ្ហាទី១។ នាពេលនេះ អង្គជំនុំជម្រះស្តាប់សារណារបស់ភាគីលើបញ្ហាទី១ ជាមុនសិន។ ហើយអង្គជំនុំជម្រះសូមរំឭកថា កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានសម្រេចតែងតាំងអ្នកជំនាញ 2-TCE-1062 ហើយអ្នកជំនាញរូបនេះ នឹងមកផ្តល់សក្ខីកម្មនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦។

កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ អង្គជំនុំជម្រះបានបង្គាប់តាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ថា ឲ្យគូភាគី ជូនដំណឹងមកអង្គជំនុំជម្រះ ប្រសិនបើខ្លួនមានបំណងក្នុងការដាក់សំណើ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ 2-TCE-1062 ឲ្យបានត្រឹមថ្ងៃទី០៦ ខែធ្នូ។ ហើយអង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់ និងសារណាឆ្លើយតបទាំងឡាយនៅថ្ងៃទី០៧ ខែធ្នូ។

កាលពីម្សិលមិញ អង្គជំនុំជម្រះបានទទួលការជូនដំណឹងពីភាគីក្រុមមេធាវីការពារក្តី នួន ជា, មេធាវីការពារក្តី ខៀវ សំផន និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថាខ្លួនគ្មានបំណងក្នុងការដាក់សំណើសុំ អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការ នឹងអ្នកជំនាញរូបនេះទេ។ ដោយឡែក មានតែសហព្រះរាជអាជ្ញា មានបំណងដាក់ឯកសារចំនួនបី ធ្វើជាឯកសារភស្តុតាង។ ហើយនៅពេលនេះ អង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់ និងចម្លើយតបរបស់ភាគីលើបញ្ហានេះ។

ហើយដំបូងនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីឡើងធ្វើសារណាផ្ទាល់មាត់ បង្ហាញអំពីសំណើសុំរបស់ខ្លួន ពាក់ព័ន្ធនឹងការដែលខ្លួនមានបំណងដាក់ឯកសារចំនួនបីជាភស្តុតាង ពាក់ព័ន្ធនឹងអ្នកជំនាញ 2-TCE-1062 នេះ។ សូមអញ្ជើញ!

[១០:១១:២៤]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេប គឺថាឯកសារទាំងបី គឺឯកសារដែលអង្គជំនុំជម្រះបានទទួលបានពីអ្នកជំនាញនោះ ហើយបានដាក់នៅក្នុងឃ្លាំងផ្ទុកឯកសាររួម កាលពីខែតុលា ឆ្នាំនេះ។ <ដូច្នេះ>ឯកសារ<ទាំងអស់នេះ> ភាគី<មិន>អាចរកបាន មុនពេលចាប់ផ្តើមសវនា

ការ<ទេ>។ គឺថាឯកសារទាំងអស់នេះ វាមានភាពពាក់ព័ន្ធចំពោះបញ្ហានៅក្នុងសំណុំរឿង រួមបញ្ចូលទាំងសក្ខីកម្មរបស់អ្នកជំនាញ។ ឯកសារពីរ<ដំបូង> គឺជាព័ត៌មាន<បន្ថែម>ទាក់ទងទៅនឹងការសិក្សាដែលគាត់ធ្វើចំពោះឆ្អឹង អដ្ឋិធាតុនៅជើងឯក។ ហើយមួយទៀត គឺជាបញ្ជីនៃភស្តុតាងដែលបង្ហាញពីចំនួនលលាដ៍ក្បាល ក៏ដូចជា ស្លាកស្នាមនៃការធ្វើទារុណកម្ម និងការសម្លាប់ផងដែរ។ ខ្ញុំគិតថា ឯកសារទាំងអស់នេះ យើងអាចប្រើប្រាស់នៅពេលដែលយើងសួរដេញដោលអ្នកជំនាញ។ ទី៣ គឺខ្ញុំចង់បញ្ជាក់ថា ឯកសារនេះ គឺជា<កិច្ច>សម្ភាសន៍<មួយ>ដែល<អ្នកជំនាញ ឬក៏>ក្រុមអ្នកជំនាញ បានធ្វើការសម្ភាសជាមួយ ហ៊ឹម ហ៊ុយ ក៏ដូចជា -- ដែល ហ៊ឹម ហ៊ុយ ដែលជាសាក្សី ស-២១ ដែលបានផ្តល់សក្ខីកម្មនៅទីនេះ។ <ដូច្នេះ យោងតាមការអនុវត្តរបស់តុលាការ យើង>គិតថា វាជាការសមស្របមួយ ក្នុងការទទួលយកការសម្ភាស ដែលគេធ្វើជាមួយ ហ៊ឹម ហ៊ុយ។ <ដូច្នេះនិយាយឲ្យខ្លីទៅ នេះគឺជាមូលដ្ឋាននៃសំណើសុំរបស់យើង ដើម្បីឲ្យ>ទទួលយកនូវឯកសារទាំង<ទាំងបី>នេះ <ដែលត្រូវបានសម្រេចទទួលយកដោយអង្គជំនុំជម្រះ>។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ – បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:១៣:១៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមលោកបញ្ជាក់បន្តិច ថាតើឯកសារហ្នឹង មានតែជាភាសាខ្មែរ ឬក៏មានភាសាផ្សេងទៀត? ខ្ញុំគិតថា ច្បាប់ដើមជាភាសាខ្មែរ មិនដឹងថា មានការបកប្រែ ឬក៏អត់?

**លោក ឌេល លីសាក់៖**

បាទ លោកចៅក្រម ឯកសារទាំងអស់ ត្រូវបានបកប្រែជាពីរភាសា។ ហើយសារអេឡិចត្រូនិកដែលខ្ញុំបានធ្វើ គឺថាបានបញ្ជាក់អំពីលេខ ERN របស់ឯកសារទាំងអស់នេះ ទាំងគ្រប់ភាសា។ ដូច្នេះខ្ញុំចង់បញ្ជាក់ឡើងវិញ គឺឯកសារនេះ ត្រូវបានបកប្រែរួចរាល់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការឆ្លើយតប ឬក៏កត់សម្គាល់ទៅលើសំណុំរបស់សហព្រះរាជអាជ្ញា អម្បាញ់មិញនេះ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំគោរពទៅតាមការសម្រេចទាំងស្រុងរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា។

[១០:១៤:៣៦]

**លោក វិចទ័រ កូប៉េ៖**

បាទ លោកប្រធាន យើងមិនមានការជំទាស់ចំពោះសំណើនេះទេ ប៉ុន្តែខ្ញុំមានការឆ្ងល់មួយចំនួនទាក់ទងទៅនឹងភាពពាក់ព័ន្ធនៃការសម្ភាសជាមួយ ហ៊ឹម ហ៊ុយ។ ប៉ុន្តែខ្ញុំជឿជាក់ថា ការសម្ភាសនេះគឺវាពាក់ព័ន្ធដែរ ដើម្បីឱ្យយើងអាចវាយតម្លៃទៅលើវិធីសាស្ត្រស្រាវជ្រាវដែលអ្នកជំនាញបានធ្វើឡើង។ ហេតុដូច្នេះហើយ ទើបយើងខ្ញុំមិនជំទាស់ចំពោះការទទួលយកឯកសារនេះធ្វើជាភស្តុតាង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហមេធាវីការពារក្តី ខៀវ សំផន!

**កញ្ញា អង់តា ហ្គិសសេះ**

យើងខ្ញុំមិនមានការកត់សម្គាល់ជាក់លាក់អ្វីទៅលើឯកសារពីរដំបូងទេ។ ហើយឯកសារទី៣ ជាប្រតិចារឹក ឬក៏ជាសេចក្តីសង្ខេបរបស់ ហ៊ឹម ហ៊ុយ នោះ ខ្ញុំមិនដឹងទេ។ ហើយបើតាមខ្លឹមសារនោះ ដូចជាគ្មានអ្វីថ្មីទេ បើធៀបទៅនឹងចម្លើយដែលគាត់បានឆ្លើយជូនអង្គជំនុំជម្រះ និងចម្លើយពីមុនរបស់គាត់។ អ៊ីចឹងយើងអត់មានជំទាស់អីទេ លោកប្រធាន។

[១០:១៥:៥៦]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយឥឡូវនេះ ចូលដល់បញ្ហាទី២ អង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់របស់ភាគីលើបញ្ហានេះ គឺបញ្ហាពាក់ព័ន្ធសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកាលពីរសៀលថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ហើយបានសួរដេញដោលដោយភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញារួចហើយ។ ហើយលោក ស សារិន ក៏បានបះបង់ការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅពាក់កណ្តាលទី

ដោយលោក ស សារិន ចូលរួមនៅក្នុងសវនាការក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី ដូច្នេះអង្គជំនុំជម្រះមិនអាចចាត់វិធានការបង្ខំឲ្យគាត់មកបង្ហាញខ្លួន និងបន្តផ្តល់សក្ខីកម្មបញ្ចប់នៅចំពោះមុខអង្គជំនុំជម្រះបានឡើយ។

ហើយរំឭកថា កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីតាមរយៈអ៊ីម៉ែល មន្ត្រីច្បាប់ជាន់ខ្ពស់ថា អង្គជំនុំជម្រះនឹងសម្រេចដកដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ចេញពីបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយកាលពីម្សិលមិញនេះ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះមានបំណងស្តាប់សារណាផ្ទាល់មាត់របស់ភាគី ពាក់ព័ន្ធនឹងការប្រើប្រាស់ភស្តុតាងដាក់បន្ទុកដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី ស សារិន។

ហើយជាដំបូងនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការធ្វើសារណាផ្ទាល់មាត់ -- អ៊ំ! បាទ ជូនទៅខាងលោក វ៉ិចទ័រ កូប៉េ ដែលជាម្ចាស់សំណើ សូមឲ្យបញ្ជាក់បញ្ហានេះ។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១០:១៧:៣៤]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន គឺថាតាមពិតទៅ គឺយើងខ្ញុំជាអ្នកស្នើសុំអង្គជំនុំជម្រះដើម្បីអនុញ្ញាតឲ្យមានការលើកសារណាដោយផ្ទាល់មាត់ ទាក់ទងទៅនឹងសាក្សី សារិន – ស សារិន។ ដូចដែលអង្គជំនុំជម្រះក៏ដូចភាគីបានដឹងច្បាស់ហើយ យើងធ្លាប់មានប្រវត្តិជាមួយ ស សារិន តាំងពី០០២/០១ មកម្ល៉េះ។ គាត់ត្រូវបានគេកោះហៅមកផ្តល់សក្ខីកម្ម ប៉ុន្តែភ្លាមៗហ្នឹង គាត់សម្រេចចិត្តថា គាត់មិនចង់ផ្តល់សក្ខីកម្មបន្ថែម បន្តទៀត។ ដូច្នេះខ្ញុំគិតថា យើងកំពុងតែបន្តប្រវត្តិដដែលៗឡើងវិញ ប៉ុន្តែក្រោយមកទៀត ព្រះរាជអាជ្ញាបានស្នើសុំឲ្យកោះហៅគាត់មកផ្តល់សក្ខីកម្ម ហើយចុងក្រោយ គាត់បែរជាមិនផ្តល់បន្តទៅទៀត។ ដូច្នេះខ្ញុំគិតថា វាជារឿងភ្ញាក់ផ្អើលមួយ ដែលឥឡូវនេះស្រាប់តែគាត់ថា គាត់អាចមកផ្តល់សក្ខីកម្មបាន សម្រាប់០០២/០២ នៅក្នុងតុលាការនេះទៅវិញ។

យើងទាំងអស់គ្នាបានដឹងហើយថា គាត់បានឆ្លើយសំណួររបស់ព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី។ បន្ទាប់មកទៀត យើងក៏សម្រាក នៅពេលនោះ ប្រសិនបើខ្ញុំចាំមិនខុស ដោយសារយើងអស់ពេលវេលា ហើយគាត់គ្រោងថា នឹងមកផ្តល់ចម្លើយសម្រាប់ក្រុមមេធាវីការពារក្តី។ ក៏ប៉ុន្តែ

ដូចដែលលោកប្រធានបានបញ្ជាក់រួចមកហើយអ៊ីចឹង យើងបានទទួលនូវអ៊ីម៉ែលពីមន្ត្រីច្បាប់មួយ ដែលបង្ហាញថា គាត់ឈឺ ហើយមិនអាចមកផ្តល់សក្ខីកម្មបាន។ ប៉ុន្តែមានម្តងនោះ យើងបានទទួលនូវរបាយ-ការណ៍មួយ មកពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលផ្តល់មកដល់ភាគីនានា នៅចុងខែមុន គឺ E29/501 ដែលនោះគឺជារបាយការណ៍ ដែលនៅក្នុងរបាយការណ៍នោះគឺថា ស សារិន បានបញ្ជាក់ប្រាប់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ថាគាត់មិនចង់ផ្តល់សក្ខីកម្ម ប្រសិនបើគាត់មិនទទួលបានការអនុញ្ញាតឲ្យទៅរស់នៅប្រទេសទី៣។

[១០:២០:១៥]

ហើយនៅពេលដែលគាត់ជជែកជាមួយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ គាត់បានបញ្ជាក់ថាគាត់ស្នើសុំឲ្យតុលាការនេះជួយគាត់ ក៏ដូចជា ជួយអន្តរាគមន៍ទៅដល់សំណើរបស់គាត់ទៅរស់នៅប្រទេសទី៣ ដោយធ្វើការស្នើសុំដល់ទូត ឬក៏អង្គការក្រៅរដ្ឋាភិបាលនៅប្រទេសកម្ពុជាដើម្បីជួយគាត់។

ខ្ញុំគិតថា គាត់មានការព្រួយបារម្ភជាច្រើន ដូចដែលគាត់លើកឡើងនៅឆ្នាំ២០១៣ អ៊ីចឹងដែរ។ ម៉្យាងវិញទៀត ខ្ញុំចាំថា វាមានការផ្តល់អនុសាសន៍ពីខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលអង្គភាពនេះបានបញ្ជាក់ថា របាយការណ៍ថ្ងៃ២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ គឺថាអង្គភាពគាំពារសាក្សី និងអ្នកជំនាញមិនអាចលុបបំបាត់នូវការភ័យខ្លាចកម្រិតខ្ពស់របស់លោក ស សារិន។ ហើយម៉្យាងទៀត អង្គភាពវី.ស៊ូ ក៏មិនអាចរកឃើញអំពីមូលដ្ឋានណាមួយដែលជាលទ្ធផល គឺលោក ស សារិន បានស្នើសុំវិធានការការពារនៅក្នុងតុលាការ នៅក្នុងសំណុំរឿង០០២/០១ មុនពេលដែលគាត់បន្តផ្តល់សក្ខីកម្ម។ ហើយបន្ទាប់មកទៀត គាត់មិនបានទទួល។

ពេលនេះគឺអង្គភាពគាំពារសាក្សីនិងអ្នកជំនាញបាននិយាយថា ស សារិន មិនបានចង់ មិនស្នើសុំវិធានការការពារទេ ប៉ុន្តែសូមសិទ្ធិរស់នៅប្រទេសទី៣។ <វាហាក់បីដូចជា មិនស៊ីសង្វាក់គ្នាជាមួយនឹងការបង្ហាញពីការព្រួយបារម្ភរបស់គាត់ ចំពោះអតីតទាហានខ្មែរក្រហម ដែលសងសឹកប្រឆាំងនឹងគាត់ចំពោះការសហការរបស់គាត់ ជាមួយនឹងតុលាការនេះ។> ហើយបន្ទាប់មកទៀត អង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានបញ្ជាក់ថា អង្គភាពមិនអាចផ្តល់អនុសាសន៍អំពីវិធានការការពារណាមួយបន្ថែមទៀតបានឡើយ។

[១០:២២:៣៩]

យើងយល់ស្រប ឬក៏យើងអាចនិយាយថា យើងយល់បានអំពីអនុសាសន៍បែបនេះ ហើយយើង

ជឿជាក់ថា យើងគ្មានមូលហេតុអ្វីដើម្បីទទួលយកនូវហេតុផលដែល ស សារិន បានផ្តល់ទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញនោះឡើយ។

ពិតណាស់ថា បញ្ហាសំខាន់គឺតើយើងគួរធ្វើយ៉ាងណា ដោយសារអង្គជំនុំជម្រះបានបញ្ជាក់ថា មិនចង់ស្តាប់សក្ខីកម្មរបស់គាត់បន្ថែមទៀត។ តើយើងគួរធ្វើយ៉ាងណាជាមួយភស្តុតាង ដែលគាត់បានផ្តល់រួចទៅហើយ នៅពេលដែលគាត់ឆ្លើយតបទៅនឹងសំណួររបស់ព្រះរាជអាជ្ញា ហើយនិងសហមេធាវីនាំមុខ។ គឺថាមានភស្តុតាងជាច្រើន ដែលគាត់បានផ្តល់នៅក្នុងតុលាការនេះនៅថ្ងៃ០៨ វិច្ឆិកា ដែលមេធាវីការពារក្តីមានការបារម្ភដែរ។ លោកប្រធាន ប្រហែលជាលោកនៅចាំ គឺមានម្តងខ្ញុំបានងើបឈរឡើង ហើយប្រតិកម្មទៅនឹងសំណួរពីខាងព្រះរាជអាជ្ញា ដែលខ្ញុំលើកឡើង គឺថានិយាយអំពីភាពពាក់ព័ន្ធនៃសាក្សីជាមួយនឹងតួនាទីរបស់ជនជាប់ចោទ។ ហើយម៉្យាងចំពោះការកសាងទំនប់ យើងមិនមានបញ្ហាអីនោះទេ ប៉ុន្តែយើង ហើយយើងក៏មិនគ្រោងនឹងសំណួរទាក់ទងនឹងចំណុចនេះដែរ ប៉ុន្តែមានប្រធានបទមួយដ៏សំខាន់ដែលខ្ញុំត្រៀមរួចរាល់ហើយ ថានឹងសួរគាត់នោះ។ នោះគឺប្រធានបទដែលលើកឡើងដោយព្រះរាជអាជ្ញាផងដែរ គឺប្រធានបទដែលនិយាយអំពីបញ្ហា ថាតើអតីតមន្ត្រីរដ្ឋការ និងទាហានលន់ នល់ហ្នឹងត្រូវបានគេសម្លាប់ដែរឬអត់ នៅក្នុងតំបន់បូព៌ាដែលគាត់រស់នៅ។

ប្រហែលជាលោក លោកស្រីចៅក្រមនៅចាំនៅឡើយ ថាព្រះរាជអាជ្ញាបានសួរសាក្សីដោយដកស្រង់នូវសម្រង់ចេញពីចម្លើយ ឬក៏ការសម្ភាសរបស់ អ៊ុក ប៊ុនឈឿន ដែល អ៊ុក ប៊ុនឈឿន គាត់ផ្តល់ទៅឱ្យ ប៉ែន យៀវនិន។ យើងជំទាស់ទៅលើបញ្ហានេះ ដោយសារតែយើងគិតថា វាមិនអាចតំណាងអំពីបញ្ហា <ហើយគាត់គួរតែលើកឡើងអំពីសម្រង់សម្តី>សក្ខីកម្មរបស់ ហេង សំរិន ផងដែរ។ <វាហាក់បីដូចជា>អង្គជំនុំជម្រះតុលាការកំពូល<>យល់ស្របជាមួយគោលជំហរ<នេះ> ក៏ដូចជាសំអាងហេតុដែលបានបញ្ជាក់រួចរាល់ហើយនៅក្នុងសាលដីកា<លើបណ្តឹងសាទុក្ខ នាពេលថ្មីៗនេះ>។

[១០:២៥:៣០]

អ្វីដែលមេធាវីការពារក្តីបារម្ភខ្លាំងនោះ គឺគាត់ជាសាក្សីមួយរូប<ដំបូង> ដែលមកបង្ហាញខ្លួននៅទីនេះ ហើយគាត់បានផ្តល់ភស្តុតាងអំពីលទ្ធភាព ដែលថាអាចមានការសម្លាប់មន្ត្រីរដ្ឋការ និងទាហានលន់ នល់ នៅភូមិភាគបូព៌ា។

ដូចដែលអង្គជំនុំជម្រះបានដឹងច្បាស់ ប៉ែន យៀវនិន ហើយនិងសៀវភៅដែលគាត់បាននិពន្ធនោះគឺ<> “របបប៉ុល ពត” គឺបានព្យាយាមយ៉ាងច្រើនដើម្បីបង្ហាញថា មិនមានគោលនយោបាយនៅភូមិ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភាគបូព៌ា គឺគោលនយោបាយសម្លាប់ទាហាននិងមន្ត្រីរដ្ឋការលន់ នល់ នៅភូមិភាគបូព៌ានោះ<ទេ>។

ខ្ញុំអាចនិយាយទាក់ទងទៅនឹងឯកសារ <E3/1593> អង់គ្លេសមានលេខ – ខ្ញុំមានសម្រង់ ប៉ុន្តែខ្ញុំនឹងបង្ហាញលេខ ERN នៅពេលក្រោយ។ គឺគាត់និយាយអំពីការដោះលែងអតីតមន្ត្រីរដ្ឋការ<>លន់ នល់ ៤00នាក់ ដែលពួកគាត់ត្រូវបានគេអនុញ្ញាតឲ្យត្រឡប់ទៅគ្រួសារ។ ហើយ<>មាន ៥៨0នាក់ <ផ្សេងទៀត ដែលជា> ទាហាន លន់ នល់ ដែលត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅភូមិវិញ។ ដោយសារតែយើងមានសាក្សីមួយរូបដែលគាត់អាចនឹងនិយាយផ្ទុយពីភស្តុតាងមួយនេះ <ថាតើវាគឺជារឿងពិត ឬក៏អត់នោះ អ្វីដែលគាត់បានបញ្ជាក់ គាត់បានឮនោះ គឺថាវាគឺជា>បញ្ហាមួយទៀតដែរ។ ហើយអ្វីដែលសំខាន់សម្រាប់យើងខ្ញុំផងដែរនោះ <បើសិនបើ>ភស្តុតាងរបស់គាត់ វាអាចត្រឹមត្រូវ<នោះ> មានន័យថា អ្នកដែលទទួលខុសត្រូវលើការសម្លាប់ គឺអ្នកដែលគួរត្រូវបានកោះហៅមកទីនេះផងដែរ។

[១០:២៧:៣៨]

ហើយគាត់ត្រូវបានលើកឡើងនៅក្នុងសំណើជាច្រើន ហើយគាត់នោះគឺ អ៊ុក ប៊ុនឈឿន ព្រោះ <រឿងនេះកើតឡើងនៅក្នុងស្រុករបស់គាត់ ដែល>មានការចោទប្រកាន់ថា<>ការសម្លាប់មនុស្ស <អាចប្រព្រឹត្តឡើងនៅទីនោះ>។ ប្រសិនបើគាត់មិនមក ប្រាកដណាស់ថា ខ្ញុំដឹង ថាខ្ញុំមិនអាចសួរដេញដោលសាក្សីអំពីបញ្ហានេះទេ។ ក៏ប៉ុន្តែផលវិបាកនោះ គឺថាភស្តុតាងដែលគាត់ផ្តល់នៅពេលដែលគាត់ឆ្លើយសំណួររបស់ព្រះរាជអាជ្ញានោះ គួរតែលុបចោល ឬក៏ចាត់ទុកថាមិនអាចប្រើប្រាស់បាន ដោយសារតែមេធាវីការពារក្តីមិនមានឱកាសក្នុងការសួរដេញដោល។

ខ្ញុំគិតថាតាមផ្លូវច្បាប់ វាជាការពិភាក្សាដ៏គួរឲ្យចាប់អារម្មណ៍ ទាក់ទងទៅនឹងភស្តុតាងដែលបានផ្តល់នៅក្នុងតុលាការរួចទៅហើយនោះ។ ហើយខ្ញុំជឿជាក់ថា វាមានភាពខុសគ្នាមួយរវាងប្រព័ន្ធខំមិនឡនិងប្រព័ន្ធស៊ីវិលឡ ព្រោះក្នុងប្រព័ន្ធខំមិនឡ គឺថាយើងអាចទទួលយកភស្តុតាងលុប គឺថាលុបចោលភស្តុតាងទាំងស្រុងពីកំណត់ត្រា ប៉ុន្តែចំពោះប្រព័ន្ធស៊ីវិល គឺវាពិបាកមែនទែន ដោយសារតែចៅក្រមវិជ្ជាជីវៈគួរតែអាចពិចារណាទៅលើភស្តុតាងបែបនេះបាន។

ខ្ញុំគិតថា ស្ថានភាពកន្លងមកនៅក្នុងតុលាការនេះ គឺថាវាមានលក្ខណៈមួយ ក៏ប៉ុន្តែសំណើរបស់ខ្ញុំៗគិតថា ចង់ឲ្យមានការពិចារណាឡើងវិញ លើការកោះហៅ<គាត់ម្តងទៀតចូល>មកអង្គជំនុំជម្រះនេះ<>។ ហើយខ្ញុំថាលោក ស សារិន មិនអាចថា បដិសេធទៅលើដីកាកោះនោះទេ ប៉ុន្តែប្រសិនបើមិនមានការសម្រេចនោះទេ ខ្ញុំគិតថាដើម្បីប្រយោជន៍យុត្តិធម៌ ភស្តុតាងដែលគាត់បានផ្តល់គួរតែត្រូវលុប

ចេញពីកំណត់ត្រា។ នេះគឺជាគោលជំហររបស់យើងខ្ញុំ។ សូមអរគុណលោកប្រធាន។

[១០:៣០:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើសារណាតបទៅនឹងសំណើសុំ ឬក៏បង្ហាញរបស់សហមេធាវីការពារក្តី នួន ជា អម្បាញ់មិញនេះ។

ចង់បន្ថែម ឬក៏ធ្វើក្រោយ ចាំធ្វើក្រោយគេ លោកសហមេធាវីការពារក្តី ខៀវ សំផន?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដើម្បីឱ្យមានលក្ខណៈពេញលេញចំពោះចម្លើយរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី គឺឱ្យខ្ញុំនិយាយសិនទៅលោកប្រធាន ដើម្បីកុំឱ្យមានឆ្លើយតបគ្នាទៅវិញទៅមកពីរបីជាន់។ ប៉ុន្តែខ្ញុំគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ។ ខ្ញុំគិតថា ដោយសារតែយើងមានទស្សនៈដូចគ្នាទៅលើចំណុចមួយចំនួន ជាមួយនឹងមេធាវីការពារក្តី នួន ជា។ អ៊ីចឹងខ្ញុំគិតថា ខ្ញុំផ្តល់គោលជំហររបស់យើងខ្ញុំនៅពេលនេះឱ្យហើយ។ តាមការសម្រេចរបស់អង្គជំនុំជម្រះ។

អ៊ីចឹងខ្ញុំឃើញថា លោកប្រធានអនុញ្ញាតហើយ។ សូមអរគុណ។

ខាងមេធាវីការពារក្តីលោក ខៀវ សំផន គោលជំហររបស់យើង គឺមានលក្ខណៈដាច់ណាត់ជាងខាងមេធាវី នួន ជា ពីព្រោះយើងយល់ឃើញថា បញ្ហាហ្នឹងគឺច្បាស់ណាស់។ តើយើងត្រូវធ្វើយ៉ាងម៉េចចំពោះសក្ខីកម្មរបស់ ស សារិន ដែលបានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះ គឺច្បាស់ណាស់ យើងមិនអាចយកមកពិចារណាបានទេ។

[១០:៣១:៥០]

ខ្ញុំសូមពន្យល់មូលហេតុ។ យើងនៅចំពោះមុខតុលាការមួយ ដែលដកស្រង់ចេញពីច្បាប់ស៊ីវិលឡូ ហើយនិងខំមិនឡូ រួមគ្នា។ អ៊ីចឹងរហូតមកដល់ពេលថ្ងៃនេះ គោលការណ៍របស់អង្គជំនុំជម្រះ គឺត្រូវបានបញ្ជាក់ដោយអនុស្សរណៈនេះ គឺយើងត្រូវតែគោរពគោលការណ៍ចំពោះមុខ ដែលជាគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ នៅពេលដែលយើងកោះហៅសាក្សីជាក់លាក់ ឬដើមបណ្តឹងរដ្ឋប្បវេណីរូបណាមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺយើងត្រូវគិតពិចារណាទៅលើសក្ខីកម្មរបស់គាត់ ត្រូវតែមានការសួរដេញដោលពីភាគីទាំងអស់ គឺសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា អង្គជំនុំជម្រះ និងមេធាវីការពារក្តី។ ប្រសិនបើមេធាវីការពាក្តីមិន

<មាន>ឱកាសក្នុងការសួរដេញដោលបុគ្គលរូបនោះទេ គឺការដេញដោលចំពោះមុខនោះ គឺមិនប្រព្រឹត្តទៅបានពេញលេញទេ។ ដូច្នេះក្នុងលក្ខខណ្ឌបែបនេះ គឺភស្តុតាងនេះ គ្មានសុពលភាពទេ។ យើងមិនអាចយកមកប្រើប្រាស់បានទេ។

មេធាវីការពារក្តីលោក ខៀវ សំផន សូមបញ្ជាក់ថា យើងយល់ឃើញថា មានការលំបាករហូតមកដល់សព្វថ្ងៃនេះ ដោយសារ តែខ្ញុំសូមយោងទៅលើសារណារបស់យើងគឺ E305/9 ដែលចុះខែឧសភា ឆ្នាំ២០១៤ គឺថ្ងៃទី៣០ ឧសភា ឆ្នាំ២០១៤។ នៅពេលដែលយើងដឹងថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាស្នើសុំជាថ្មីម្តងទៀត ឲ្យអង្គជំនុំជម្រះកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន <ត្រឡប់>មកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ។ យើងគិតថាដូចជាហួសហេតុហើយ ដូចដែលមេធាវី នួន ជា បានបញ្ជាក់ហើយ គឺយើងមានយុត្តិសាស្ត្រនៅក្នុងសំណុំរឿង ០០២/០១រួចមកហើយ គឺគាត់បង្ហាញវត្តមានពីរដង នៅចំពោះមុខអង្គជំនុំជម្រះ ហើយគាត់ប្រកែកពីរដងក្នុងការបន្តផ្តល់សក្ខីកម្ម មិនឲ្យគេសួរគាត់ទៀត។ អ៊ីចឹងដូចនៅក្នុងសំណុំរឿង០០២/០២ គាត់បដិសេធមិនព្រមឆ្លើយ ក្រោយពីសហព្រះរាជអាជ្ញា និង មេធាវីនាំមុខសួរចប់។

[១០:៣៤:១៧]

ខ្ញុំសូមរំឮកនូវអ្វីដែលយើងបាននិយាយនៅក្នុងកថាខណ្ឌ៣៨ នៃសារណានោះ។ ខ្ញុំសូមដកស្រង់មេធាវីការពារក្តីប្រឆាំងទៅនឹងការកោះហៅគាត់នេះ គឺថាវាមានលក្ខណៈដដែលៗ ហើយវាគ្មានប្រយោជន៍អ្វីទេ ដោយយោងទៅតាមបទពិសោធន៍នៅក្នុងសំណុំរឿង ០០២/០១ រួចមកហើយ ហើយធ្វើឲ្យអង្គជំនុំជម្រះជួបបញ្ហា និងការសើចចំអក ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនអាចគ្រប់គ្រងបាន ហើយមិនអាចជឿទុកចិត្តបាន។ អ៊ីចឹងយើងបានបាត់បង់ពេលវេលាជាច្រើនទៅលើដើមបណ្តឹងរដ្ឋប្បវេណីរូបហ្នឹង។

អ៊ីចឹងថ្ងៃនេះ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦នេះ ដែលយើងត្រូវមកគិតបញ្ហាដដែល ទៅលើលោក ស សារិន នោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីនោះ គាត់មានសិទ្ធិមិនអាចផ្តល់សក្ខីកម្មបាន គាត់មិនមែនជាសាក្សីទេ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណី <ដូច្នេះ គាត់មានសិទ្ធិដូចគ្នាទៅនឹងជនជាប់ចោទម្នាក់យោងតាមសក្ខីកម្មរបស់គាត់>។ អ៊ីចឹងគាត់បានបង្ហាញអំពីឥរិយាបថរបស់គាត់ នៅក្នុងសំណុំរឿង ០០២/០១រួចមកហើយ ហើយនិងថ្មីៗនេះ ក្នុងសំណុំរឿង០០២/០២នេះ គឺគាត់ជាមនុស្សម្នាក់មួយដែលមិនទៀងទាត់។ អ៊ីចឹងគាត់ដូចជាលេងសើចជាមួយនឹងសវនាការយើងហ្នឹង។ គាត់មិនចង់ឲ្យមានការតតាំង

គាត់មិនចង់ឲ្យមានការសួរដេញដោលពីខាងមេធាវីការពារក្ដីទេ។ អ៊ីចឹងមិនអាចយកមកប្រើបានទេចំពោះភស្តុតាងរបស់គាត់នោះ ទោះបីជាផ្នែកណាមួយក៏ដោយនៃសក្ខីកម្មរបស់គាត់នោះ។ អ៊ីចឹងគោលជំហររបស់យើង គឺច្បាស់ណាស់ លោក ស សារិន មិនចង់មកផ្ដល់សក្ខីកម្មបន្តទេ។

[១០:៣៥:៥៧]

ហើយខ្ញុំសូមបញ្ជាក់ថា របាយការណ៍របស់អង្គភាពគាំពារសាក្សី អ្នកជំនាញហ្នឹង <>ដែលមេធាវី នួន ជា លើកឡើងនោះ។ មុនហ្នឹងយើងមានហើយ ហើយយើងឃើញថា <មានការលើកឡើងអំពីដំណើរចាកចេញពីបន្ទប់សណ្ឋាគាររបស់លោក ស សារិន មិនទាន់ពេលវេលា> គាត់មានការអល់អែកនៅពេលដែលគាត់ផ្ដល់សក្ខីកម្មពាក់កណ្ដាលហើយ ហើយយើងមិនអាចគ្រប់គ្រងគាត់បានទេ។ អ៊ីចឹងយើងឃើញថា លក្ខណៈនេះគឺជាលក្ខណៈដដែលៗ គឺទង្វើដដែលៗរបស់ ស សារិន ដែលគាត់ប្រព្រឹត្តបែបហ្នឹង។ អ៊ីចឹងយើងមិនអាចយកសក្ខីកម្មរបស់គាត់មកប្រើបានទេ។

ផ្ទុយពីជំហររបស់មេធាវី នួន ជា <គឺថាវាមិនមែនជាបញ្ហាសាមញ្ញនោះទេ ក្នុងការចោះយកសក្ខីកម្មរបស់គាត់ដោយផ្នែកៗនោះទេ។> យើងមិនអាចផ្អែកទៅលើចម្លើយរបស់លោក ស សារិន បានទេ ទោះបីជាផ្នែកណាមួយក៏ដោយ គឺគោលជំហររបស់យើង គឺរឹងមាំណាស់ គឺថាមិនអាចយកមកប្រើប្រាស់បានទេ ភស្តុតាងរបស់គាត់នោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការឆ្លើយតប ទៅនឹងបញ្ហាដែលលើកឡើងដោយសហមេធាវីការពារក្ដីទាំងពីរក្រុមនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានមតិបន្តិចបន្តួច ទាក់ទងទៅនឹងលោក កូប៉េ។ លោក កូប៉េ គាត់បាននិយាយថា ជាបញ្ហាស្មុគស្មាញផ្លូវច្បាប់។ ដូច្នេះខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាយើងលើកយកមកនិយាយដោយផ្ទាល់មាត់ ម៉េចក៏មិនសរសេរជាលាយលក្ខណ៍អក្សរទៅ។--

[១០:៣៧:៤១]

**ប្រធានអង្គជំនុំ៖**

សូមៗផ្អាកបន្តិច ដោយសារត្រូវការផ្លាស់ប្ដូរឌីស វាអស់ឌីស។

*(ផ្លាស់ប្ដូរឌីវីឌី)*

បាទ សូមអញ្ជើញបន្ត សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ឡើងវិញ ក្នុងករណីដែលយើងមិនបានកត់ត្រា។ មេធាវីការពារក្តី នួន ជា បានទទួលស្គាល់ថា វាជាបញ្ហាស្មុគស្មាញខ្លាំងផ្នែកផ្លូវច្បាប់។ ដូច្នេះចំពោះខ្ញុំ ខ្ញុំយល់ថា ប្រសិនបើដូច្នេះមែន យើងគួរតែសរសេរជាសារណា មុនពេលដែលធ្វើការសម្រេចជាចុងក្រោយ។ ចំពោះបញ្ហាដែលត្រូវបន្តទៅមុខ ថាតើនាំគាត់យកមកទីនេះឬក៏អត់ អានោះគឺជាបញ្ហាមួយផ្សេង។ ខ្ញុំ<យល់ អង្គជំនុំជម្រះបានសម្រេចចិត្តរួចហើយថា នឹងមាន>សេចក្តីសម្រេចមួយ<នាពេលខាងមុខនេះ ដែលយើងមិនបានឃើញនោះទេ។ វាគឺជាបញ្ហាមួយផ្សេងគ្នា ពាក់ព័ន្ធទៅនឹង>សក្ខីកម្មគាត់ផ្តល់ <ហើយ>យើងមិនត្រូវភ្លេចអំពីសក្ខីកម្ម ដែលគាត់បានផ្តល់នៅទីនេះ <ហើយ>គាត់បានផ្តល់ការសម្ភាសជាច្រើនជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយវា<ត្រូវបានទទួលយក>ជាភស្តុតាងមួយ។ ថាតើយើងដោះស្រាយជាមួយបញ្ហាបែបនេះដោយរបៀបណា? ខ្ញុំគិតថាយើងគួរតែសរសេរជាសារណាដោយភាគីនីមួយៗ។ ម្យ៉ាងទៀត សូម្បីខាងមេធាវីការពារក្តី ក៏មានមតិផ្សេងពីគ្នាដែរ។

[១០:៣៩:៣៤]

ឥឡូវនេះខ្ញុំចង់បញ្ជាក់ឡើងវិញ។ វាជាស្ថានភាពអកុសលមែនទែន ដែលដើមបណ្តឹងរដ្ឋប្បវេណីបដិសេធមិនមកទីនេះ។ ហើយដូចដែលលោក កូប៉េ បានបញ្ជាក់នៅក្នុងការបង្ហាញរបស់គាត់អ៊ីចឹង គឺថាលោក ស សារិន ត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម។ ហើយយើងមាន ហើយនៅក្នុងសវនាការលើកទី១ គឺថាយើងស្នើសុំឲ្យគាត់មក ក៏ប៉ុន្តែអង្គជំនុំជម្រះបានបញ្ជាក់ថា មិនមានសិទ្ធិអំណាច<ក្នុងការចាប់បង្ខំឲ្យដើមបណ្តឹងរដ្ឋប្បវេណីម្នាក់មកផ្តល់សក្ខីកម្មបានទេ។> ប៉ុន្តែការពិតទៅ វាមិនមែនជារឿងត្រឹមត្រូវនោះទេ ព្រោះថាតាមគំនិតរបស់យើង នៅពេលដែលយើងនិយាយហ្នឹង គឺយើងយល់ខុស ព្រោះថាអង្គជំនុំជម្រះមានសិទ្ធិអំណាចក្នុងការកោះហៅភាគី។ ខ្ញុំគិតថា យើងដោះស្រាយបញ្ហានេះរួចទៅហើយ។ ហើយខ្ញុំក៏មិនប្រឆាំងជាមួយលោក កូប៉េ ដែរ។ ហើយក្រុមខ្ញុំក៏ឯកភាពដែរ ទៅលើចំណុចនេះដែលថាអង្គជំនុំជម្រះមានសិទ្ធិអំណាច។ ប៉ុន្តែមេធាវី ខៀវ សំផន មានទស្សនៈផ្សេង ដែលថាអង្គជំនុំជម្រះមិនមានសិទ្ធិអំណាចក្នុងការបង្ខំឲ្យបុគ្គល<រូបនេះ>មកបង្ហាញខ្លួន<ទេ>។

ហេតុអ្វីបានជាខ្ញុំយល់ថា នេះជារឿងសំខាន់ ហើយលើកយកមកនិយាយនោះ? ព្រោះថា បុគ្គលរូបនេះ ប្រសិនបើសិនមិនមានអ្វីប្រែប្រួល ហើយគាត់មិនត្រូវបានមេធាវីការពារក្តីសួរដេញដោលនោះទេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងយល់ស្របថា សក្ខីកម្មរបស់គាត់នៅក្នុងតុលាការនេះ ក៏ដូចជាកិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់គាត់កន្លងមកនោះ <គឺត្រូវបាន>ចាត់ទុកថា ជាចម្លើយដែលមិនបានមកផ្តល់សក្ខីកម្មនៅតុលាការនោះ <ដែលមិនត្រូវបានសួរដេញដោលដោយមេធាវីការពារជនជាប់ចោទ>។

[១០:៤១:២៨]

ខ្ញុំគិតថា យើងយល់ស្របជាមួយចំណុចនេះ។ នៅពេលដែលភាគីមិនអាចសួរដេញដោលបាន នៅពេលដែលមិនមានការសួរដេញដោលបាន គឺថាអង្គជំនុំជម្រះត្រូវតែសម្រេច<ឲ្យបានលម្អិត> ពិចារណាទៅលើភស្តុតាងបែបនេះ<> ព្រោះថាភស្តុតាងបែបនេះ <អាចត្រូវបានពិចារណាថា>មានទម្ងន់<កម្រិតកំណត់> ហើយម្យ៉ាងទៀត វានិយាយអំពីតួនាទីរបស់ជនជាប់ចោទ ដូច្នេះ<វាមិនអាចត្រូវបានពិចារណាទេ លុះត្រាតែសាក្សី ត្រូវបានពិចារណាថាមិនអាចមកបាន>។

ដូច្នេះខ្ញុំគិតថា វាមានសេចក្តីសម្រេចលើបទដ្ឋានជាច្រើន ក្នុងការសម្រេច ថាតើត្រូវដោះស្រាយជាមួយបញ្ហាបែបនេះដោយរបៀបណា។ ចំពោះស្ថានភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយនេះ គឺថាយើងមិនមានឱកាសក្នុងការស្រាវជ្រាវ ថាតើ ប្រសិនបើមនុស្សណាម្នាក់ដែលតុលាការកោះហៅ ហើយបដិសេធ ថាតើយើងគួរតែអនុវត្តដោយរបៀបណា។ ខ្ញុំមិនមានចម្លើយចំពោះបទដ្ឋានបែបនេះទេ។ ប៉ុន្តែខ្ញុំគិតថា បញ្ហានេះ គួរតែសរសេរជាសារណា ឬក៏ជាលាយលក្ខណ៍អក្សរ ទាក់ទងទៅនឹងសាក្សីដែលមិនអាចត្រូវបានសួរដេញដោលបាន។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំយល់ស្របថា ប្រសិន<បើជាបុគ្គលរូបនេះ>មិនត្រូវបានសួរដេញដោលទេ <គឺថារាល់>ភស្តុតាង<ទាំងអស់របស់គាត់ គឺត្រូវបានចាត់ទុកថាចម្លើយដែលមិនបានមកផ្តល់នៅចំពោះមុខ>តុលាការ។

**ប្រធានអង្គជំនុំ៖**

បាទ ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៤៣:២៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងធ្វើការកត់សម្គាល់មួយចំនួនដែលដឹកនាំដោយគោលការណ៍នៃការប្រយ័ត្នប្រយែង ព្រោះថានេះវាជាបញ្ហាស្មុគស្មាញ ហើយយើងមិនមានលទ្ធភាពក្នុងការធ្វើការស្រាវជ្រាវស៊ីជម្រៅ ហើយខ្ញុំសូមឆ្លើយតបទៅនឹងសំណើរបស់មេធាវី កូប៉េ ឲ្យបានច្បាស់លាស់បំផុតតាមដែលអាចធ្វើទៅបាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាបឋម ខ្ញុំសូមបញ្ជាក់ថា យើងមិនមានការសង្ស័យអ្វីទេ ថាអង្គជំនុំជម្រះនឹងអនុវត្តវិធានច្បាប់ គឺការជំនុំជម្រះដោយយុត្តិធម៌។ ជាពិសេសគឺ<>សិទ្ធិរបស់<មេធាវីការពារក្តី> ក្នុងការសួរដេញដោលសាក្សី<> ពីព្រោះថា សិទ្ធិនេះគឺជាសិទ្ធិដែលបញ្ជាក់ច្បាស់ដោយតុលាការកំពូលរួចមកហើយ នៅក្នុងសាលដីកា ដែលមាននៅក្នុងកថាខណ្ឌ២៨៧។ ពាក់ព័ន្ធនឹងសំណើដំបូងរបស់មេធាវីការពារក្តីដែលសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីនេះមកវិញនោះ ច្បាស់ណាស់ថា យើងមិនអាចបង្ខំឱ្យដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្ម<>នៅចំពោះមុខអង្គជំនុំជម្រះនេះ<ម្តងទៀតទេ>។ គោលជំហររបស់យើងគឺច្បាស់ណាស់ គឺដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងទេ ដែលបាត់បង់ឱកាសក្នុងការមកបង្ហាញសក្ខីកម្មរបស់គាត់ នៅចំពោះមុខអង្គជំនុំជម្រះ។ ពេលដែលគាត់ប្រកែកមិនមកនេះ អ៊ីចឹងគឺថាគាត់ផ្តាច់លទ្ធភាពខ្លួនឯងក្នុងការចូលរួមចំណែកក្នុងការលាតត្រដាងការពិត និងបង្ហាញអំពីព្យសនកម្មដែលគាត់ទទួលរង ហើយនិងមូលហេតុដែលគាត់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៤៥:២២]

អ៊ីចឹងចំពោះចំណុចទី១ ដែលលើកឡើងដោយមេធាវីការពារក្តី លោក នួន ជា នោះអង្គជំនុំជម្រះសាលាដំបូងមិនអាចបង្ខំឱ្យដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះបានទេ។ ខ្ញុំឯកភាពទាំងស្រុងចំពោះមេធាវី កូប៉េ ក្នុងការនិយាយថាវាមានភាពខុសគ្នាច្រើន រវាងប្រព័ន្ធច្បាប់ស៊ីវិលឡូ និងខំមិនឡូ។

ដូច្នេះខ្ញុំយល់ឃើញថា យើងមិនអាចធ្វើតាមអ្វីដែលមេធាវីការពារក្តី នួន ជា លើកឡើងថាឱ្យលុបចោលនូវសក្ខីកម្មរបស់គាត់ ទោះបីជាគាត់មិនបានផ្តល់សក្ខីកម្មដល់ចប់ក៏ដោយនោះទេ។ សក្ខីកម្មរបស់គាត់ គឺជាផ្នែកមួយនៃប្រតិចារឹកសវនាការ។ អ៊ីចឹងបញ្ហាយើងចង់ដឹង ថាតើអង្គជំនុំជម្រះនឹងប្រើប្រាស់ព័ត៌មានទាំងអស់នេះយ៉ាងដូចម្តេច។ បើសិនបើមេធាវីការពារក្តីយល់ឃើញថា ព័ត៌មាននេះត្រូវបានប្រើប្រាស់ដោយមិនត្រឹមត្រូវនោះ គឺគាត់អាចប្តឹងសាទុក្ខបាន។ ក៏ប៉ុន្តែខ្ញុំមើលទៅ ដូចថាមិនឃើញហេតុផលអីដែលត្រូវលុបចោលសក្ខីកម្មរបស់គាត់ចេញពីប្រតិចារឹក<សវនាការ> -- សក្ខីកម្មរបស់គាត់ ដែលគាត់បានផ្តល់ជាសាធារណៈនោះទេ។

[១០:៤៦:៤៨]

ដូច្នេះតាមទស្សនៈរបស់យើង សក្ខីកម្មរបស់គាត់គឺជាផ្នែកមួយនៃប្រតិចារឹក។ ការសួរដេញដោលជាផ្ទាល់មាត់អាចឱ្យអង្គជំនុំជម្រះដឹងអំពីគោលជំហររបស់ភាគី <ជាពិសេសគឺជំហររបស់មេធាវី

ការពារក្តី ដែលជឿថា រាល់>សក្ខីកម្មរបស់<ស សារិន ទាំងអស់ គួរតែត្រូវបានទុកមួយឡែកនៅក្នុងបរិបទនៃការពិភាក្សា។ វាអាស្រ័យទៅលើ>អង្គជំនុំជម្រះ<ក្នុងការទទួលយកការ>សម្រេច<របស់លោក ប្រកបដោយសម្បជញ្ញៈច្បាស់លាស់ ដើម្បីដឹងថាតើលោកនឹងប្រើ>សក្ខីកម្ម<នេះដោយរបៀបណា>។ អ៊ីចឹងហើយមេធាវីការពារក្តីគាត់មានលទ្ធភាពប្តឹងសាទុក្ខទៀត បើសិនជាអង្គជំនុំជម្រះប្រើប្រាស់នូវសក្ខីកម្មរបស់គាត់នោះ។ <ខ្ញុំមិនដឹងថាតើយើងអាចធ្វើអ្វីផ្សេងទៀតបានដោយរបៀបណានោះទេ ក្រៅពី>គោរពលើគោលការណ៍<ដែលខ្ញុំទើបតែលើកឡើងនេះ>នេះ។

ហើយជាថ្មីម្តងទៀត គឺយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ គឺក្នុងរយៈពេល ២ឆ្នាំនេះមកហើយ យើងតែងតែនិយាយថា យើងខ្ញុំតែងតែគោរពទៅនឹងមេធាវីការពារក្តី ទៅនឹងសិទ្ធិរបស់មេធាវីការពារក្តី។ អ៊ីចឹងយើងព្យាយាមស្វែងរកសំណាងទៅតាមនោះដែរ។ ទោះជាយ៉ាងណាក៏ដោយ គឺយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

ឈប់! ឈប់! កុំអាលទាន់!

សូមអញ្ជើញ! សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មុនពេលដែលយើងធ្វើការពិភាក្សាវែងឆ្ងាយនោះ ខ្ញុំចង់សូមពេលពីរបីនាទី ដើម្បីពិភាក្សានៅក្នុងក្រុមប្រឹក្សាចៅក្រមសិន។

[១០:៤៨:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៣:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ដែលផ្តល់វេទិកានេះឲ្យខ្ញុំ ខ្ញុំចង់បានការពន្យល់ពីសំណាក់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសគឺពីមេធាវីផ្ទាល់របស់លោក ស សារិន ផ្ទាល់តែម្តង។ ខ្ញុំចង់ដឹងថា សព្វថ្ងៃនេះលោក ស សារិន នៅតែរក្សាទុកនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

ប្បវេណីរបស់គាត់ដដែល ឬក៏យ៉ាងណា? ព្រោះថាយើងឃើញថា ឥរិយាបថរបស់គាត់ហ្នឹង គឺដូចវាមិនស៊ីសង្វាក់គ្នាសោះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះ។

ដូច្នេះ តើមេធាវីផ្ទាល់របស់លោក ស សារិន មានបានទាក់ទងផ្ទាល់ជាមួយនឹងកូនក្តីរបស់ខ្លួនទេ ហើយគាត់មានបានប្រាប់ថាគាត់ចង់ធ្វើអីទេ? ម្ខាងគាត់មិនចង់ចូលរួមផ្តល់សក្ខីកម្មជាមួយអង្គជំនុំជម្រះអ៊ីចឹងម្ខាងទៀត យើងចង់ដឹងថា គាត់នៅតែចង់រក្សាឋានៈគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីដដែល ឬក៏យ៉ាងម៉េច? អស់លោកមានព័ត៌មានច្បាស់លាស់ ពាក់ព័ន្ធនឹងចំណុចនេះជូនអង្គជំនុំជម្រះទេ?

[១០:៥៤:៤៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ លោកចៅក្រម ឡាវ៉ែន៍ ខ្ញុំសូមផ្តល់ចម្លើយមួយផ្នែកសិន ព្រោះថាមេធាវីគាត់អត់មកទេថ្ងៃនេះ។ យោងតាមរបាយការណ៍របស់ វី.ស៊្សូ លោកដឹងហើយថាមានការទូរស័ព្ទនិយាយគ្នាជាមួយលោក ស សារិន និងមេធាវី។ អ៊ីចឹងមានន័យថា មេធាវីរបស់គាត់ហ្នឹង បានទាក់ទងជាមួយកូនក្តី ស សារិន ហ្នឹងហើយ។ ហើយបើលោកចៅក្រមចង់បាន យើងនឹងទាក់ទងទូរសព្ទទៅលោកមេធាវី វ៉ែន ពៅ ផ្ទាល់ ដើម្បីអាចឲ្យគាត់ឆ្លើយផ្ទាល់ ឬក៏ពេលឈប់សម្រាកអាហារថ្ងៃត្រង់ហ្នឹងយើងអាចជជែកគ្នាជាមួយមេធាវី វ៉ែន ពៅ ហើយនិងយើងនឹងផ្តល់ព័ត៌មានតាមក្រោយ ថាតើគាត់បានពិភាក្សាជាមួយនឹងកូនក្តីគាត់ គឺលោក ស សារិន ហ្នឹងយ៉ាងម៉េចខ្លះ ហើយគាត់ចង់ដកឋានៈគាត់ចេញវិញ ដកពាក្យសុំតាំងខ្លួនចេញវិញ ឬក៏យ៉ាងម៉េចនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

ខ្ញុំគិតថា ត្រូវតែសួរសំណួរឲ្យបានច្បាស់ទៅកាន់លោក ស សារិន ហើយយើងចង់បានចម្លើយនុ៎ង ឲ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន។ ខ្ញុំគិតថា វាមានសារៈសំខាន់សម្រាប់ការពិភាក្សាបន្តទៅទៀតរបស់យើង។

[១០:៥៦:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេប ចំពោះការសង្កេតរបស់សហមេធាវីនាំមុខ ទាក់ទងទៅនឹងឋានៈរបស់លោក ស សារិន។ ប្រាកដណាស់ថា វាជាការត្រឹមត្រូវដែលគាត់បានចូលក្នុងសវនាការនេះ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែខ្ញុំមិនអាចដកស្រង់នូវកថាខណ្ឌជាក់លាក់

ណាមួយនៅក្នុងសាលដីកា<នៃបណ្តឹងសាទុក្ខ>នោះទេ។ ប៉ុន្តែអ្វីដែលខ្ញុំអាចនិយាយបាននៅពេលនេះ គឺថាយើងបានដាក់នូវមូលដ្ឋានបណ្តឹងសាទុក្ខជាច្រើន ទាក់ទងទៅនឹងឋានៈ ក៏ដូចជាការប្រព្រឹត្តខុសគ្នាចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាសក្ខីកម្មដែលផ្តល់ដោយសាក្សី។ ខ្ញុំមិនអាចអាននូវសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលឲ្យច្បាស់លាស់នោះទេ ប៉ុន្តែអ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាសាលដីកាបានបញ្ជាក់ថា នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមកទីនេះ ផ្តល់ភស្តុតាង ទោះបីថា គាត់<បានស្បថ ឬមិនបានស្បថ> គឺថាមិនមានអ្វីពាក់ព័ន្ធនោះទេ ពេលនុំងគឺថាគាត់ក្លាយទៅជាសាក្សីពិតប្រាកដរួចទៅហើយ។ ហើយភស្តុតាងដែលបុគ្គលនេះផ្តល់ឲ្យ ទោះបីថាគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មិនក៏ដោយ គឺថាភស្តុតាងនេះ គឺអាចជួយដល់ការសម្រេចទៅលើពិរុទ្ធភាពបាន។

វាជាការពិតដែលថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចកោះហៅមកបាន មិនអាចបង្ខំឲ្យមកបាន ប៉ុន្តែអង្គជំនុំជម្រះនៅតែមានសិទ្ធិអំណាចក្នុងការកោះហៅបុគ្គលណាម្នាក់ ដែលខ្លួនយល់ថាមានសារៈសំខាន់។ ប៉ុន្តែអ្វីដែលខ្ញុំចង់បញ្ជាក់គឺថា នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មអំពីឯកសារព័ត៌មាននានា គឺគាត់គួរតែចាត់ទុកថាជាសាក្សី។

<ហើយចំពោះអ្វីដែលមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយថា>ដើមបណ្តឹងរដ្ឋប្បវេណីគាត់មានសិទ្ធិក្នុងការស្ម័គ្រចិត្តមក<បង្ហាញខ្លួន ខ្ញុំជឿថា វាត្រឹមត្រូវហើយ គឺនៅតែពេលដែលគាត់មកទីនេះ ដើម្បីថ្លែងអំពី>ផលប៉ះពាល់ <និងព្យសនកម្មក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ប៉ុណ្ណោះ>។ ដូច្នេះប្រសិនបើគាត់មកផ្តល់ភស្តុតាង មកផ្តល់សក្ខីកម្មជាឯកសារភស្តុតាង ឬក៏ជាភស្តុតាងនោះ គឺគាត់គួរត្រូវ<ប្រព្រឹត្តឲ្យដូចជា>ជាសាក្សី<ផ្សេងទៀត>។

[១០:៥៨:៥០]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន ខ្ញុំមានចំណុចពីរឆ្លើយតប។ អ្វីដែលលោកមេធាវី កូប៉េ បាននិយាយហ្នឹង គឺថាខ្ញុំសូមបញ្ជាក់ថា យើងមានវប្បធម៌គតិយុត្តិច្បាស់លាស់។ <ប៉ុន្តែវាច្បាស់ណាស់សម្រាប់ខ្ញុំ ហើយត្រឡប់ទៅនឹងសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ គឺថា>ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការណាមួយឡើយ ប្រសិនបើខ្លួនមិនចង់មកនោះ បើគាត់មិនចង់ផ្តល់សក្ខីកម្មនោះ។ ចាប់ពីពេលមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីពេលពួកគាត់មានមេធាវី អ៊ីចឹងយើងមិនអាចបង្ខំគាត់បានទេ ហើយវាមិនមានផលប៉ះពាល់អីទៅលើពាក្យសុំតាំងខ្លួនជា

ដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ទេ។

ចំពោះចំណុចទី១ គឺថាពាក់ព័ន្ធទៅនឹងតម្លៃភស្តុតាងនៃព័ត៌មាន ដែលនឹងត្រូវផ្តល់ជូនតុលាការនោះ ឬក៏លទ្ធផលនៃផលវិបាកដែលកើតចេញពីធាតុផ្សំផ្សេងទៀត ដែលបានផ្តល់ជូននោះ គឺវាច្បាស់ណាស់សម្រាប់ខ្ញុំ។> យើងមកពីប្រព័ន្ធច្បាប់មួយដែលមានដើមបណ្តឹងរដ្ឋប្បវេណី<ចូលរួម> អ៊ីចឹងសួរសំណួរ ថាតើខ្ញុំនៅរក្សាទុកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីឬក៏អត់ បើខ្ញុំមិនផ្តល់សក្ខីកម្មនោះ មិនចោទជាបញ្ហាទេ គាត់នៅតែជាដើមបណ្តឹងរដ្ឋប្បវេណីដដែល ទោះបីជាគាត់មិនផ្តល់សក្ខីកម្មក៏ដោយ។

ចំណុចទី២ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ គឺថាយើងមិនទាន់<ឮ>សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទៅលើបញ្ហានេះនៅឡើយទេ ក៏ប៉ុន្តែវាជាចំណុចមួយ ដែលយើងឲ្យមានការពិភាក្សាគ្នានៅថ្ងៃនេះ គឺមានអ៊ីម៉ែលរបស់អ្នកច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ ចុះថ្ងៃទី<២២> ខែ១១ ឆ្នាំ២០១៦ គឺនៅម៉ោងប្រាំបី ហាសិបប្រាំបី<នាទី នាព្រឹកនេះ> នៅពេលដែលឆ្លើយតបទៅនឹងសំណួររបស់ នួន ជា សុំដកជាភាសាអង់គ្លេស៖ “អង្គជំនុំជម្រះសាលាដំបូង បានសម្រេចទម្លាក់ចោលដើមបណ្តឹងរដ្ឋប្បវេណី។ <មូលហេតុ នឹងត្រូវផ្តល់ជូននៅក្នុងសេចក្តីសម្រេចនាពេលខាងមុខ>។”

[១១:០០:៤៥]

អ៊ីចឹងគឺថាការទម្លាក់ចោល ឬក៏ការដកចេញពីបញ្ជីជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានន័យថាអង្គជំនុំជម្រះលែងចង់ស្តាប់គាត់ទៀតហើយ។ អ៊ីចឹងហើយ ដោយសារតែអង្គជំនុំជម្រះមិនចង់បន្តស្តាប់សក្ខីកម្មរបស់គាត់ គឺដកគាត់ចេញពីបញ្ជីនោះ មានន័យថា គេដក មានការសម្រេចរួចមកហើយ ត្រង់ចំណុចហ្នឹង។ អ៊ីចឹងយើងទាញផលវិបាកទៅតាមហ្នឹងទៅ។ អ៊ីចឹងការបង្ខំកោះហៅហ្នឹង វាមិនមែនជាបញ្ហាដែលត្រូវធ្វើទេ ព្រោះថាអង្គជំនុំជម្រះបានសម្រេចដកគាត់ចេញពីបញ្ជីទៅហើយ យើងប្រើពាក្យអង់គ្លេសថា “*ដ្រប់*” នេះ – “*ដ្រប់*” មានន័យថា “ដកចេញៗ” លែងចង់ស្តាប់គាត់ទៀតហើយ <នេះគឺយោងតាម មន្ត្រីច្បាប់ជាន់ខ្ពស់។ ដូច្នេះសម្រាប់ខ្ញុំ ការពិភាក្សានេះ ត្រូវបានបញ្ចប់ហើយ>។ អ៊ីចឹងឥឡូវសំណួរហ្នឹង មិនមែនថា កោះហៅ ឬមិនកោះហៅទៀតទេ យើងចង់ដឹង ថាតើត្រូវធ្វើយ៉ាងម៉េច ចំពោះសក្ខីកម្មរបស់<ដើមបណ្តឹងរូបនេះ គឺពាក់ព័ន្ធនឹងកិច្ចការរបស់យើងក្នុងការត្រៀមរៀបចំ ដើម្បីសរសេរសេចក្តីសន្និដ្ឋានស្តាពររបស់យើង>។

ដូច្នេះគោលជំហររបស់យើង គឺច្បាស់ណាស់ គឺយើងបញ្ជាក់ហើយថា យើងបានចំណាយពេលច្រើនណាស់មកហើយលើសំណុំរឿង០០២/០១ និងសំណុំរឿង០០២/០២ ដើម្បីសួរដើមបណ្តឹងរដ្ឋ

ប្បវេណីរូបនេះហ្នឹង ថាគាត់ចង់ ឬមិនចង់ផ្ដល់សក្ខីកម្មនោះ អ៊ីចឹងយើងចំណាយពេលច្រើនហើយកុំខាតពេលទៅលើបុគ្គលរូបហ្នឹង ម្នាក់ហ្នឹងទៀតអី។ យើងទុកចោលទៅ សក្ខីកម្មរបស់គាត់នោះ ទុកចោលទៅ យើងមិនបាច់ប្រើប្រាស់ទេ នៅពេលដែលអង្គជំនុំជម្រះពិភាក្សាសម្រេច<ចំពោះបញ្ហាហ្នឹង> គឺទុកចោលទៅ មិនបាច់គិតយកមកធ្វើជាបានការអីទេ ភស្តុតាងរបស់គាត់នោះ។

[១១:០២:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ នៅរាល់មតិយោបល់របស់ភាគី ពាក់ព័ន្ធនឹងបញ្ហាទាំងពីរ អង្គជំនុំជម្រះសម្រេចដូច្នេះ។ ចំពោះបញ្ហាទី១ គឺសំណើរបស់សហព្រះរាជអាជ្ញា សូមដាក់បង្ហាញ ដាក់ឯកសារចំណួនបីធ្វើជាឯកសារភស្តុតាង គឺអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិនិត្យពិចារណា ចេញសេចក្ដីសម្រេចឆាប់ៗ ក្នុងពេលខាងមុខនេះ។ បញ្ហាទី២ ពាក់ព័ន្ធទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្ដី នួន ជា ដែលលើកឡើងអំពីបញ្ហានៃការប្រើប្រាស់ភស្តុតាងដាក់បន្ទុក ដែលបានផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយតាមមតិភាគច្រើន គឺនៃអង្គចៅក្រមអង្គជំនុំជម្រះ សម្រេចថា សុំឱ្យ ដោយសារបញ្ហាទាំងផ្លូវច្បាប់ ទាំងអង្គហេតុ រឿងហេតុនេះពាក់ព័ន្ធហ្នឹង គឺវាមានតែចរិតស្មុគស្មាញ ហើយគួរទីជាទីចាប់អារម្មណ៍។ ដូច្នេះអង្គជំនុំជម្រះភាគច្រើនហ្នឹង គឺចៅក្រមភាគច្រើននៃ អ.វ.ត.ក សម្រេចថា ឱ្យភាគីដាក់សារណាជាលាយលក្ខណ៍អក្សរមក ដើម្បីអង្គជំនុំជម្រះពិនិត្យពិចារណា សម្រេចនាពេលខាងមុខ ឬក៏សម្រេចនៅក្នុងអំឡុងពេលនៃដំណើរការវិភាគ--

**ចៅក្រម យូរ ឧត្តរា៖**

បកប្រែខុសៗ ឱ្យដាក់ជាលាយលក្ខណ៍អក្សរ។

[១១:០៤:០៤]

**ប្រធានអង្គជំនុំ៖**

បញ្ជាក់ម្ដងទៀត ក្រែងលោនិយាយមិនច្បាស់ ខ្ញុំឃើញចៅក្រមនៅជិតខ្ញុំហ្នឹង ដូចជាវា ដូចជាខ្ញុំនិយាយអត់ត្រូវសោះតែម្ដង ខ្ញុំនិយាយពីកន្លងមក ដូចមិនដែលត្រូវម៉េច។ ហើយចម្លែកតែគាត់មួយដែរនេះ។ ដូចមិនឃើញមិនត្រូវ និយាយៗមិនៗត្រូវ។ និយាយឡើង គាត់ជ្រះជ្រួល ជ្រះជ្រួល មិនដឹងយ៉ាងម៉េច។

ឥឡូវហ្នឹងសម្រេចឱ្យភាគីដាក់សារណាជាលាយលក្ខណ៍អក្សរលើបញ្ហានេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចប់ហើយ យើងលែងឲ្យនិយាយអីទៀតហើយ។ បញ្ហានេះចប់ហើយណ៎ា អត់ឲ្យនិយាយអីទៀតទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំចង់សួរបញ្ជាក់ឲ្យបានច្បាស់ ដើម្បីឲ្យសារណារបស់យើងមានលក្ខណៈពេញលេញនោះ ថាតើយើងត្រូវសរសេរយ៉ាងម៉េចខ្លះ? យើងចង់ដឹងពីទឡ្ហីករណ៍របស់អង្គជំនុំជម្រះ ថាអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានអីដែលដកគាត់ចេញពីបញ្ជីនោះ យើងចង់ឲ្យដឹងច្បាស់ពីទឡ្ហីករណ៍របស់អង្គជំនុំជម្រះ ដើម្បីយើងសរសេរសារណាហ្នឹងបានពេញលេញ។

**ប្រធានអង្គជំនុំ៖**

តាមខ្ញុំចាំ គឺជាភាសាខ្មែរ ខ្ញុំមិនទាន់បានចុះហត្ថលេខាលើសេចក្ដីសម្រេចថា ដកគាត់ទេ គ្រាន់តែប្រជុំផ្ទៃក្នុងទេ។ ចំពោះភាសាអង់គ្លេសថាដកនុ៎ង គឺខ្ញុំមិនដឹងទេ។ ទី២ ជំហររបស់ខ្ញុំជាប្រធានសវនាការពិតណាស់គឺដក ដាច់ខាតដកតែម្ដង។ មិនយកបញ្ហានេះមកដោះស្រាយទៀតទេ ថាដក មិនដកអីនេះគឺៗមិនទេ ព្រោះយើងបានប្រជុំឯកភាពគ្នារួចហើយ។ ខ្ញុំមិនផ្លាស់ប្ដូរជំហនេះទេ ទោះបីចៅក្រមផ្សេងទៀតផ្លាស់ប្ដូរក៏ដោយ។ ប៉ុន្តែបញ្ហានេះ គឺបញ្ហាដែលលើកឡើងដោយ វ៉ិចទ័រ កូប៉េ គឺត្រង់ថា សក្ខីកម្មរបស់ ស សារិន ដែលបានផ្ដល់រួចហើយនេះ យកធ្វើជាភស្តុតាងសម្រាប់ជាមូលដ្ឋានសរសេរសាលក្រមបានដែរឬអត់? ជាពិសេសគឺភស្តុតាងដាក់បន្ទុក ដែលគាត់ដាក់បង្ហាញនេះ បញ្ហាគឺចោទឡើងត្រង់ចំណុចនេះទេ។ ចំពោះបញ្ហាផ្សេងទៀតហ្នឹង គឺជាបញ្ហាលើកឡើងអំមិញទេ វាមិនមែនជាមូលបញ្ហា ដែលជាការលើកឡើងរបស់ភាគីដែលម្ចាស់សំណើទេ។ ដូច្នេះ ឲ្យម្ចាស់សំណើមកដាក់មកសិន ថាគាត់មានបញ្ហាអីអ៊ីចឹងភាគីផ្សេងទៀតពាក់ព័ន្ធ គឺយោងទៅលើសំណើសារណាជាលាយលក្ខណ៍អក្សររបស់ភាគីដែលមានបញ្ហា គឺសរសេរឆ្លើយតបទៅនឹងបញ្ហាប៉ុននុ៎ងឯង។ បើសិនជាមានបញ្ហាអីផ្សេងទៀតគឺដោះស្រាយផ្សេងទៀត ឬក៏ដោះស្រាយបន្ថែម។

[១១:០៧:១៧]

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ ដោយសវនាការនៅសប្ដាហ៍នេះបានប្រព្រឹត្តទៅបានឆាប់រហ័ស និងមិនមានដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីបម្រុងទេនោះ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃត្រឹមនេះ សវនាការលើអង្គសេចក្ដីពិនិត្យភស្តុតាងលើកទៅបន្តធ្វើនៅថ្ងៃខានស្អែក ថ្ងៃសុក្រ ទី០៩ ខែធ្នូ ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយសវនាការនៅថ្ងៃសុក្រ ថ្ងៃទី០៩ ខែធ្នូ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-971 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្តរមានជ័យ។ ដោយឡែកថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៨ ខែធ្នូ ឆ្នាំ២០១៦ អង្គជំនុំជម្រះនឹងធ្វើការប្រជុំរៀបចំសវនាការ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:០៩ នាទី)*